ក

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

៣១-៨-២០០២	- ព្រះរាជក្រម នស/រកម/០៨០២/០១៦ ច្បាប់ស្តីពីព្រៃឈើ	២៥៣៧

២. ព្រះរាជក្រឹត្យ

០៤-៩-២០០២	- ព្រះរាជក្រឹត្យ នស/រកត/០៩០២/២៦០ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ញាតូបនីយកម្ម ដល់លោក **ឡៀង តូម៉ាស** (LEON TOMAS) ដើមកំណើតចិន សញ្ជាតិព័រទុយហ្គាល់ នៅក្រុងម៉ាកាវ ប្រទេសចិន	២៥៩៣
០៤-៩-២០០២	- ព្រះរាជក្រឹត្យ នស/រកត/០៩០២/២៦១ ស្តីពីការតែងតាំង ឯកឧត្តម **លី ទណ្ឌាថន** ជាទីប្រឹក្សា កិត្តិយសរបស់ឯកឧត្តម **ញឹក ប៊ុនឆៃ** អនុប្រធានទី ២ នៃព្រឹទ្ធសភា	២៥៩៤
០៤-៩-២០០២	- ព្រះរាជក្រឹត្យ នស/រកត/០៩០២/២៦៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ញាតូបនីយកម្ម ដល់លោក **លឹង ហោះហ្វា** (LEUNG FOR WA) សញ្ជាតិដើមចិន កើតនៅក្រុងហុងកុង ប្រទេសចិន	២៥៩៥

II- រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

១១-៩-២០០២	- អនុក្រឹត្យ លេខ ៩៤ អនក្រ បក ស្តីពីបែបបទនិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជនបរទេស ជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជន ក្នុង ព្រះរាជាណាចក្រកម្ពុជា	២៥៩៦
១៣-៩-២០០២	- អនុក្រឹត្យ លេខ ៩៥ អនក្រ បក ស្តីពីការបង្កើតក្រុមហ៊ុនជលផល ជាសហគ្រាសសាធារណៈ	២៦០១
១០-៩-២០០២	-អនុក្រឹត្យ លេខ ៤៣៧ អនក្រ តត ស្តីពីការតម្លើងឋានន្តរសក្តិ នាយនគរបាលជាតិជាកិច្ច បច្ឆាមរណៈ ជូនចំពោះសព វីរសេនីយ៍ទោ **សួស តារាពៅ**	២៦១១
១០-៩-២០០២	- អនុក្រឹត្យ លេខ ៤៣៨ អនក្រ តត ស្តីពីការជូនមេដាយការងារ	២៦១២
១០-៩-២០០២	- អនុក្រឹត្យ លេខ ៤៣៩ អនក្រ តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២៧០៨
១០-៩-២០០២	- អនុក្រឹត្យ លេខ ៤៤០អនក្រ តត ស្តីពីការជូនមេដាយសហមេត្រី	២៧០៩

២. សេចក្តីសំរេច

០៦-៩-២០០២	- សេចក្តីសំរេចលេខ ៤៥ សសរ ស្តីពីការបង្កើតគណៈកម្មការទិវាសប្តាហ៍វប្បធម៌ អាស៊ាន លើកទី ១ ឆ្នាំ ២០០២	២៧១០
១២-៩-២០០២	- សេចក្តីសំរេចលេខ ៤៦ សសរ ស្តីពីការបង្កើតក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្ត និងពិនិត្យ ដោះស្រាយ ចំពោះគំរោងអភិវឌ្ឍន៍ កោះកោងកាងរបស់ក្រុមហ៊ុន កោះកោងកាង អភិវឌ្ឍន៍ គ្រុប	២៧១៣

ព្រះរាជក្រម

នស / រកម / ០៨០២ /០១៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីព្រៃឈើ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើទី ៧ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ច្បាប់
ស្តីពី
ព្រៃឈើ

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះកំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការអភិវឌ្ឍន៍និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌ ។

មាត្រា ២.-

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី ។

រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផល អនុផលព្រៃឈើរបស់សហគមន៍មូលដ្ឋាន ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

មាត្រា ៣.-

ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

ការគ្រប់គ្រងព្រៃលិចទឹកស្ថិតនៅក្រោមច្បាប់មួយដោយឡែក ។

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទមានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ ចំពោះរាល់បទល្មើសព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ១៤ នៃច្បាប់នេះ ។ សកម្មភាពនេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិខាងលើ ។

មាត្រា ៤.-

ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសក្តានុពលភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅ លើជីវភាពសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការចូលរួមជាសាធារណៈ ។

សកម្មភាពចម្បងៗពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អាក្រក់ដល់សង្គមនិងបរិស្ថាន ចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជានិងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ។ ឯកសារនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន ។

រាល់ការសម្រេចចុងក្រោយលើរាល់សកម្មភាពចម្បងៗ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ។ ការសម្រេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ ។

មាត្រា ៥.-

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ និងមានអត្ថន័យសម្រាប់ច្បាប់នេះត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ។

ជំពូកទី ២

រដ្ឋបាលព្រៃឈើ

មាត្រា ៦.-

រដ្ឋបាលព្រៃឈើគឺជាអាជ្ញាធររដ្ឋាភិបាល ដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្នុងការគ្រប់គ្រងព្រៃឈើ និងធនធានព្រៃឈើស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់នេះ ។

រដ្ឋបាលព្រៃឈើមានរចនាសម្ព័ន្ធគ្រប់គ្រង ចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយដែលបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

រដ្ឋបាលព្រៃឈើត្រូវបំពេញភារកិច្ចរបស់ខ្លួន ស្របតាមគោលការណ៍តម្លាភាព ដោយធានានូវសិទ្ធិរបស់សាធារណជន ដើម្បីចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្តលើការគ្រប់គ្រង ការប្រើប្រាស់ប្រកបដោយនិរន្តរភាព និងការអភិរក្សព្រៃឈើ ។

មាត្រា ៧.-

រដ្ឋបាលព្រៃឈើត្រូវបំពេញនូវភារកិច្ចដូចតទៅ :

១- ធានាដល់ការគ្រប់គ្រងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ប្រកបដោយនិរន្តរភាពដោយដាក់បទបញ្ជាលើរាល់សកម្មភាពព្រៃឈើ ។

២- សិក្សាប្រមូលទិន្នន័យលើព្រៃឈើរដ្ឋទាក់ទងនឹងកត្តាវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បីកំណត់នូវកំរិតផ្ដល់ផលប្រកបដោយនិរន្តរភាព ។

៣- វាយតម្លៃព្រំប្រទល់ ធ្វើការចាត់ថ្នាក់ និងកំណត់ផែនព្រៃឈើ ដើម្បីបង្កើតផែនទីប្រើប្រាស់ដីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដោយសម្របសម្រួលជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ។

៤- រៀបចំ និងអនុវត្តផែនការគ្រប់គ្រងព្រៃឈើជាតិនៅថ្នាក់នីមួយៗ នៃរដ្ឋបាលព្រៃឈើ ។

៥- បង្កើនការដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរិល និងដីព្រៃទំនេរ។

៦- បង្កើនការអភិវឌ្ឍន៍កិច្ចព្រមព្រៀង និងកម្មវិធីសហគមន៍ព្រៃឈើ ដោយផ្ដល់នូវជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់សហគមន៍តាមការសមស្រប ។

៧- អភិវឌ្ឍ និងអនុវត្តកម្មវិធីស្រាវជ្រាវ ការពារនិងថែរក្សាធនធានព្រៃឈើនិងសត្វព្រៃ ។

៨- ចាត់វិធានការសមស្របដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់ការបំផ្លិចបំផ្លាញព្រៃឈើ ភ្លើងឆេះព្រៃ និងការកាប់រានព្រៃឈើ ដោយធានាការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព ។

៩- បង្កើនការអប់រំដល់ប្រជាពលរដ្ឋតាមរយៈកម្មវិធីដែលបង្ហាញពីសារៈសំខាន់ក្នុងការគ្រប់គ្រង ការពារថែរក្សាធនធានព្រៃឈើ ក៏ដូចជាចាត់វិធានការស្ដារប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ និងថែរក្សាព្រៃឈើជាតិ ។

១០- បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅពង្រឹងសមត្ថភាពការពារនិងអភិវឌ្ឍធនធានព្រៃឈើ ។

១១- ធានាការវាយតម្លៃទាន់ពេលវេលា និងពេញលេញនូវរាល់សកម្មភាពទាក់ទងនឹងព្រៃឈើដែលមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថានមុនការឯកភាពលើសកម្មភាពទាំងនេះ។

មន្ត្រីរដ្ឋបាលព្រៃឈើមានសិទ្ធិនិងភារកិច្ចដូចខាងក្រោម :

១- ត្រួតពិនិត្យការធ្វើអាជីវកម្មប្រមូលផល អនុផលព្រៃឈើក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងចំការដាំឈើរបស់រដ្ឋ ។

២- ត្រួតពិនិត្យការដឹកជញ្ជូនផល អនុផលព្រៃឈើ និងផលប្រមាញ់តាមមធ្យោបាយដឹកជញ្ជូននានា ។

៣- ត្រួតពិនិត្យកន្លែងសន្និធិផល អនុផលព្រៃឈើ ទីតាំងលក់ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ។

៤- ត្រួតពិនិត្យមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ និងឡគ្រប់ប្រភេទដែលប្រើប្រាស់ផលអនុផលព្រៃឈើ ជាវត្ថុធាតុដើម ឬប្រភពថាមពលអំពីឈើ ។

៥- ត្រួតពិនិត្យអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារផ្សេងទៀតដែលតម្រូវឱ្យត្រួតពិនិត្យតាមច្បាប់នេះ ។

ជំពូកទី ៣

និរន្តរភាពនៃការគ្រប់គ្រងព្រៃឈើ

មាត្រា ៨.-

ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ត្រូវអនុវត្តស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិនិងច្បាប់នេះ ។

ដើម្បីជំនួយឱ្យការសិក្សាស្រាវជ្រាវគោលនយោបាយវិស័យព្រៃឈើជាតិឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងមានសមាជិកពីក្រសួងពាក់ព័ន្ធនឹងវិស័យព្រៃឈើ ។ ផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ រាជរដ្ឋាភិបាលត្រូវកំណត់នូវគោលនយោបាយវិស័យព្រៃឈើជាតិ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិត្រូវកំណត់ដោយអនុក្រឹត្យ ។

គោលនយោបាយវិស័យព្រៃឈើជាតិ អាចសើរើដោយរាជរដ្ឋាភិបាលដោយផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ ក្នុង

លក្ខខណ្ឌផ្លាស់ប្តូរនៃស្ថានភាពវិស័យព្រៃឈើតាមគោលការណ៍ដែលនាំមកនូវដំណោះស្រាយ ដើម្បីរក្សានិរន្តរភាពនៃការគ្រប់គ្រងព្រៃឈើ ។

មាត្រា ៩.-

រដ្ឋបាលព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ ដោយមានការចូលរួមទូលំទូលាយពីគ្រប់អាជ្ញាធរពាក់ព័ន្ធនិងសហគមន៍មូលដ្ឋាន ដែលអនុលោមតាមមាត្រា ៤ នៃច្បាប់នេះ ។

ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិត្រូវសម្រេចដោយរាជរដ្ឋាភិបាលសំរាប់រយៈពេលវែង ដើម្បីកំណត់អាទិភាព និងសកម្មភាពគ្រប់គ្រងព្រៃឈើ ។ ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិត្រូវធ្វើការពិនិត្យ និងសើរើរៀងរាល់ ៥ឆ្នាំ ម្តង ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌនិងកាលៈទេសៈផ្លាស់ប្តូរ ។ គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិត្រូវផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលលើផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិដែលបានសើរើ ។

ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ត្រូវលើកឡើងនូវសមាសភាគដូចតទៅ :

១- ពិនិត្យកត្តារូបសាស្ត្រ បរិស្ថាន និងសង្គមទាក់ទងនឹងធនធានព្រៃឈើនៅគ្រប់ថ្នាក់នៃរដ្ឋបាលព្រៃឈើ ។

២- ប៉ាន់ស្មានបរិមាណផល អនុផលព្រៃឈើគ្រប់លំដាប់ថ្នាក់ ។

៣- កំណត់ផ្ទៃដីតំបន់ព្រៃឈើ តំបន់ត្រូវដាំឈើឡើងវិញ និងព្រៃសហគមន៍ ។

៤- ពិនិត្យកម្មវិធី និងប្រតិទិនសកម្មភាពលំអិតលើការងាររៀបចំព្រៃឈើ និងរុក្ខវប្បកម្ម ។

៥- អភិវឌ្ឍកម្មវិធីនៃការធ្វើអន្តរាគមន៍ ដល់ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើរដ្ឋនិងឯកជន ។

៦- អភិវឌ្ឍកម្មវិធីសម្រាប់អភិវឌ្ឍន៍ឧស្សាហកម្មព្រៃឈើ ទីផ្សារផលអនុផលព្រៃឈើ ។

៧- អភិវឌ្ឍកម្មវិធីស្រាវជ្រាវ ស្តីពីការអភិវឌ្ឍន៍បច្ចេកវិជ្ជា និងវិទ្យាសាស្ត្រព្រៃឈើ ។

៨- បង្កើននិងពង្រីកចំណេះដឹងពីព្រៃឈើដោយអញ្ជើញការចូលរួមពី

សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងប្រើប្រាស់និងការពារព្រៃឈើ ។

៩- អភិវឌ្ឍធនធានមនុស្ស និងមធ្យោបាយសម្ភារៈចាំបាច់ ដើម្បីសម្រេចលើសកម្មភាពដែលបានគ្រោងនៅក្នុងកម្មវិធី ។

១០- ពង្រឹងស្ថាប័នគ្រប់គ្រងវិស័យព្រៃឈើនៅគ្រប់ថ្នាក់ កែលំអនិងពង្រឹងការអនុវត្តន៍ច្បាប់ ។

១១- ពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជំនួយបច្ចេកទេសក្នុងតំបន់និងក្រៅតំបន់ ក្នុងកិច្ចការពារនិងអភិវឌ្ឍន៍ធនធានព្រៃឈើ ។

១២- ឧបត្ថម្ភគាំទ្ររាល់កម្មវិធីទាំងឡាយណា ដែលជំរុញឱ្យមានការអនុវត្តន៍គោលនយោបាយវិស័យព្រៃឈើជាតិ ។

ផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តន៍ នូវគោលបំណងនៃផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ជូនរាជរដ្ឋាភិបាល ។ របាយការណ៍នេះ ត្រូវផ្តល់ជូនជាសាធារណៈតាមការស្នើសុំ ។

ជំពូកទី ៤
សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

មាត្រា ១០.-

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមាន :

១- ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

២- ព្រៃឯកជន ។

ព្រៃបម្រុងទុកអចិន្ត្រៃយ៍រួមមានបីប្រភេទ :

១- ព្រៃផ្តល់ផលត្រូវបានរក្សាទុកសម្រាប់ផលិតកម្មផល អនុផលព្រៃឈើប្រកបដោយនិរន្តរភាពដែលក្នុងនោះ មុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់ ។ ព្រៃផ្តល់ផលមានជាអាទិ៍ :

- ព្រៃសម្បទាន
- ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន
- ព្រៃឈើត្រូវស្តារឡើងវិញ

- ផ្ទៃដីព្រៃបម្រុងទុកសម្រាប់ដាំដើមឈើឡើងវិញ ឬចំការព្រៃឈើ
- ផ្ទៃដីព្រៃបម្រុងទុកសម្រាប់បន្តពូជព្រៃឈើ
- ផ្ទៃដីព្រៃរេចរឹល
- ព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀង ។

២- ព្រៃការពារត្រូវបានរក្សាទុកជាចម្បង ដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ ។ ព្រៃការពារមានជាអាទិ៍ :

- ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស
- ព្រៃសម្រាប់សិក្សាស្រាវជ្រាវ
- ព្រៃនិយតកម្មប្រភពទឹក
- ព្រៃការពារទីជំរាល
- ព្រៃលំហែកំសាន្ត
- សួនរុក្ខជាតិ
- ព្រៃជំនឿសាសនា ។

ព្រៃការពារនេះអាចអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណី ដែលមានផលប៉ះពាល់ទាបដោយសហគមន៍មូលដ្ឋាន ។

៣- ផ្ទៃដីព្រៃសម្រាប់ផ្ទេរដីឱ្យគោលបំណងអភិវឌ្ឍផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិព្រៃបន្ទាប់បន្សំដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវតែដាក់ឱ្យស្ថិតនៅក្នុងចំណាត់ថ្នាក់នៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ រហូតដល់មានការសម្រេចឱ្យប្រើប្រាស់ និងអភិវឌ្ឍសម្រាប់គោលបំណងផ្សេងទៀត ដោយរាជរដ្ឋាភិបាល ។

ព្រៃឯកជនត្រូវថែរក្សាដោយម្ចាស់កម្មសិទ្ធិ និងមានសិទ្ធិទទួលផលប្រយោជន៍ក្នុងការអភិវឌ្ឍន៍និងប្រមូលផលប្រើប្រាស់ លក់ចែកចាយផលិតផលរបស់ខ្លួនដោយផ្ទាល់ ។

មាត្រា ១១.-

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវគ្រប់គ្រងក្នុងគោលបំណងបង្កើនជាអតិបរមានូវផលប្រយោជន៍សង្គម សេដ្ឋកិច្ច បរិស្ថាន និងមរតកវប្បធម៌សម្រាប់ព្រះរាជាណាចក្រកម្ពុជានិងប្រជាពលរដ្ឋកម្ពុជាស្របនឹងគោលការណ៍គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទត្រូវចាត់ថ្នាក់ចុះបញ្ជីកានិងកំណត់ព្រំប្រទល់ព្រៃឈើទាំងអស់នៅក្នុងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។ ក្នុងការអនុវត្តន៍នូវសកម្មភាពនេះ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទនឹងធ្វើការសម្របសម្រួលជាមួយសហគមន៍មូលដ្ឋាន អាជ្ញាធរពាក់ព័ន្ធ និងក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ដើម្បីជួយដល់ដំណើរការចុះបញ្ជិកាកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច និងការរៀបចំផែនទីប្រើប្រាស់ដីថ្នាក់ជាតិ ។

គ្រប់ព្រៃឈើដែលបានចាត់ថ្នាក់នៅក្នុងព្រៃបំរុងទុកអចិន្ត្រៃយ៍ត្រូវបានរៀបចំ និងគ្រប់គ្រង ស្របតាមគោលបំណងនៃផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ។

នីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិអំណាចរំសាយចំណាត់ថ្នាក់ព្រៃឈើណាមួយពីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។ ការសម្រេចបែបនេះត្រូវស្ថិតនៅក្នុងផលប្រយោជន៍សាធារណៈ និងមានសង្គតិភាពជាមួយគោលនយោបាយវិស័យព្រៃឈើជាតិ ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ និងទិន្នន័យបច្ចេកទេស សង្គម សេដ្ឋកិច្ចដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ការរំសាយចំណាត់ថ្នាក់ណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ សម្រាប់គោលបំណងមិនមែនព្រៃឈើត្រូវពិចារណាលើអាទិភាព ដូចខាងក្រោម ៖

១- ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ។

២- ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ផ្សេងទៀតដែលតម្រូវការបច្ចុប្បន្នខ្ពស់ជាងតម្រូវការដែលកំណត់កន្លងមក ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទអាចស្នើសុំរាជរដ្ឋាភិបាលកំណត់រកផ្ទៃដីព្រៃទំនេរផ្សេងទៀត ដើម្បីជំនួសផ្ទៃដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលបានរំសាយក្នុងគោលបំណងការពារ និងដាំព្រៃឡើងវិញ ដើម្បីរក្សាគម្របជាអចិន្ត្រៃយ៍ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទអាចស្នើសុំរាជរដ្ឋាភិបាលសំរេចធ្វើការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃណាមួយនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដោយផ្អែកលើទិន្នន័យសិក្សាថ្មី និងមុខងាររបស់ដីព្រៃនោះ ។

រាល់ការសម្រេចរំសាយចំណាត់ថ្នាក់ព្រៃឈើដូចមានចែងក្នុងកឋាខ័ណ្ឌទី ១ និងការ

ផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃឈើដូចមានចែងក្នុងកឋាខ័ណ្ឌទី ៣ នៃមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៥
ការគ្រប់គ្រងព្រៃសម្បទាន

មាត្រា ១៣.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចផ្តល់តំបន់ព្រៃផ្តល់ផលដែលនៅទំនេរ ស្របតាមផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិទៅជាព្រៃសម្បទាន ដោយដាក់ឱ្យដេញថ្លៃជាសាធារណៈ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រោយពីបានពិគ្រោះយោបល់ជាមួយបណ្តាក្រសួងពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋានរួចហើយ ។

សំណុំឯកសារ និងនីតិវិធីនៃការដេញថ្លៃជាសាធារណៈចំពោះការផ្តល់ព្រៃសម្បទានត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

មាត្រា ១៤.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអំណាចចុះកិច្ចព្រមព្រៀងព្រៃសម្បទានជាមួយវិនិយោគិន ឬនីតិបុគ្គលណាមួយដោយការផ្តល់សម្បទាននេះ ត្រូវមានសង្គតិភាពជាមួយគោលនយោបាយវិស័យព្រៃឈើជាតិ ផែនការគ្រប់គ្រង វិស័យព្រៃឈើជាតិនិងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

ការដេញថ្លៃជាសាធារណៈ ត្រូវតែអនុវត្តជាមូលដ្ឋាននៅមុនពេលរាជរដ្ឋាភិបាលចុះកិច្ចព្រមព្រៀងព្រៃសម្បទាន ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

គណៈកម្មការដេញថ្លៃព្រៃសម្បទានត្រូវផ្តល់នូវកាលានុវត្តិភាព និងការពិចារណាជូនអ្នកដេញថ្លៃគ្រប់រូប ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងត្រូវជូនដំណឹងអំពីការដេញថ្លៃជាសាធារណៈ ឱ្យបានទាន់ពេលវេលា ជាពិសេសដល់ប្រជាពលរដ្ឋមូលដ្ឋានក្នុងតំបន់ដែលដាក់ជាព្រៃសម្បទាន ។

បេក្ខភាពក្រុមហ៊ុនដេញថ្លៃ ត្រូវភ្ជាប់រាល់ឯកសារដេញថ្លៃជាមួយនឹងលិខិតថ្លែង

ការណ៍របស់ក្រុមហ៊ុន ដែលថែងលំអិតអំពីការប្រព្រឹត្តល្អលើកិច្ចព្រមព្រៀងព្រៃសម្បទាន ដែលបានអនុវត្តកន្លងមក ទោះក្នុងប្រទេសក្តី ឬក្រៅប្រទេសក្តីដោយមានភស្តុតាងធានាអះអាងផង ។

មាត្រា ១៥.-

ព្រៃសម្បទានិកមានសិទ្ធិដំណើរការគ្រប់គ្រង និងប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនព្រៃសម្បទានរបស់ខ្លួនដោយធានាថា ប្រតិបត្តិការទាំងនេះនឹងមិនប៉ះពាល់ដល់ :

១- សិទ្ធិប្រើប្រាស់ជាប្រពៃណីដែលអនុវត្តនៅលើដីកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជិកាដោយរដ្ឋស្របតាមច្បាប់ភូមិបាល ។

២- សិទ្ធិចេញ ចូល និងសិទ្ធិប្រើប្រាស់ជាប្រពៃណី អនុវត្តដោយសហគមន៍ដែលមានទីតាំងក្នុង ឬក្បែរព្រៃសម្បទាន ។

មាត្រា ១៦.-

ខ្លឹមសារកិច្ចព្រមព្រៀងព្រៃសម្បទានក្នុងកិរិតអប្បរមាត្រូវមាន :

១- កាលបរិច្ឆេទនៃការផ្តល់ព្រៃសម្បទាន និងរយៈពេលនៃការផ្តល់ ។

២- ទីតាំងព្រៃសម្បទានដែលកំណត់បង្ហាញនូវអត្តសញ្ញាណដីកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច តំបន់ព្រៃសហគមន៍ តំបន់គ្រប់គ្រងពិសេស និងផ្ទៃដីព្រៃដែលអាចប្រមូលផលបាន ។

៣- សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរថា ព្រៃសម្បទានិកត្រូវគោរពនិងមិនជ្រៀតចូលធ្វើការប្រមូលផល អនុផលព្រៃឈើក្នុងតំបន់គ្រប់គ្រងពិសេស តំបន់កម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច និងព្រៃសហគមន៍ឡើយ ។

៤- ប្រភេទ និងបរិមាណផល អនុផលព្រៃឈើអនុញ្ញាតឱ្យប្រមូល និងវិធីសាស្ត្រគណនាបរិមាណដែលអាចដកហូតបាន ។

៥- ការបរិយាយពីកាតព្វកិច្ចរបស់ព្រៃសម្បទានិកក្នុងការកសាងនិងការអនុវត្តន៍ គំរោងផែនការគ្រប់គ្រងព្រៃឈើកម្រិតព្រៃសម្បទាន ព្រៃគុប និងប្លុកប្រមូលផល ។

៦- លក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ឬរដ្ឋបាលព្រៃឈើពាក់ព័ន្ធទៅនឹងព្រៃសម្បទាន ។

មាត្រា ១៧.-

កិច្ចព្រមព្រៀងព្រៃសម្បទាន មិនត្រូវកំណត់ឱ្យលើសពីរយៈពេលសាមសិប (៣០)ឆ្នាំ ឡើយ ។

កិច្ចព្រមព្រៀងព្រៃសម្បទានអាចបញ្ចប់ នៅពេលណាដែលរាជរដ្ឋាភិបាលបានរកឃើញថា ព្រៃសម្បទានិកបានរំលោភធ្ងន់ធ្ងរលើបណ្តាលក្ខខណ្ឌដែលតម្រូវឱ្យបញ្ចប់ ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

ព្រៃសម្បទានិកមានសិទ្ធិស្នើសុំការពន្យល់ពីមូលហេតុនៃការសម្រេចលុបចោលកិច្ចព្រមព្រៀងព្រៃសម្បទាន មុនកាលកំណត់ដោយរាជរដ្ឋាភិបាល ។ វិធានដោះស្រាយវិវាទ ត្រូវស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន និងច្បាប់ជាធរមាន ។

ដោយផ្អែកតាមការវាយតំលៃលើការអនុវត្តន៍របស់ព្រៃសម្បទានិកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជរដ្ឋាភិបាលអាចអនុគ្រោះបន្តកិច្ចព្រមព្រៀងបាន ហើយរយៈពេលបន្តនេះ មិនត្រូវលើសពីរយៈពេលកំណត់ក្នុងកិច្ចព្រមព្រៀងព្រៃសម្បទានដំបូងឡើយ ។

មាត្រា ១៨.-

ការរៀបចំផែនការគ្រប់គ្រងព្រៃសម្បទានគ្រប់កម្រិត ត្រូវទទួលខុសត្រូវដោយព្រៃសម្បទានិក តាមរបាយការណ៍ណែនាំដែលមានចែងក្នុងក្បួនធ្វើផែនការគ្រប់គ្រងព្រៃសម្បទានក្រមបច្ចេកទេសអនុវត្តប្រមូលផលព្រៃឈើនៅកម្ពុជា និងប្រការទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន ។

ព្រៃសម្បទានិកត្រូវរៀបចំផែនការគ្រប់គ្រងព្រៃសម្បទានតាមកម្រិតដូចខាងក្រោម :

១- ផែនការគ្រប់គ្រងរយៈពេលវែងសម្រាប់ព្រៃសម្បទានទាំងមូល ។

២- ផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំសម្រាប់កម្រិតព្រៃគុបនីមួយៗ ។

៣- ផែនការគ្រប់គ្រងប្លុកប្រមូលផលសម្រាប់ការប្រមូលផលប្រចាំឆ្នាំនីមួយៗ ។

ផែនការគ្រប់គ្រងព្រៃសម្បទាន និងការស្នើពីត្រូវកំណត់តាមវិធានខាងក្រោម :

១- ផែនការគ្រប់គ្រងព្រៃសម្បទានត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ ។ ផែនការនេះ

ត្រូវពិនិត្យសើរើរៀងរាល់ប្រាំ (៥)ឆ្នាំ ម្តង ។

២- ផែនការប្រមូលផលកម្រិតព្រៃគុបប្រចាំឆ្នាំ និងផែនការគ្រប់គ្រងប្លុកប្រមូលផលត្រូវសម្រេចដោយប្រធានរដ្ឋបាលព្រៃឈើ ។

មាត្រា ១៩.-

ព្រៃសម្បទានិកទាំងអស់ត្រូវតែដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងព្រៃសម្បទាននូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋាននានាស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមលើព្រៃសម្បទានដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសម្បទានត្រូវរៀបចំដោយព្រៃសម្បទានិក និងត្រូវបានពិនិត្យនិងវាយតម្លៃដោយក្រសួងបរិស្ថាន មុននឹងសម្រេចយល់ព្រមដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធានាការចូលរួមផ្តល់មតិជាសាធារណៈលើផែនការគ្រប់គ្រងព្រៃសម្បទាន និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម មុនពេលការសម្រេចចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ ។

ជំពូកទី ៦
ការគ្រប់គ្រងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន និងព្រៃការពារ

មាត្រា ២០.-

ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានត្រូវបានគ្រប់គ្រងដើម្បីបំរើជាអាទិភាពនូវសេចក្តីត្រូវការផល អនុផលព្រៃឈើប្រចាំឆ្នាំក្នុងស្រុក ។ ផល អនុផលព្រៃឈើទាំងនេះអាចធ្វើការនាំចេញបាន នៅពេលណាដែលការផ្គត់ផ្គង់លើសពីតម្រូវការប្រើប្រាស់ក្នុងស្រុក ដោយមានការសម្រេចពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ២១.-

ប្រធានផ្នែករដ្ឋបាលព្រៃឈើមានភារកិច្ចរៀបចំនិងដាក់ស្នើផែនការគ្រប់គ្រងព្រៃផ្តល់ផល ក្រៅពីព្រៃសម្បទានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជូនប្រធានរដ្ឋបាលព្រៃឈើដើម្បីពិនិត្យសម្រេច ។ ដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានត្រូវ

ប្រព្រឹត្តទៅតាមលិទាំផែនការគ្រប់គ្រងព្រៃសម្បទាន ដូចមានចែងក្នុងមាត្រា ១៨ កឋាខ័ណ្ឌទី ២ នៃច្បាប់នេះ ។

រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ណាមួយអាចដាក់ពាក្យដេញថ្លៃដើម្បីទទួលបាននូវសិទ្ធិប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ នៅក្នុងដែនព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានក្រោមនីតិវិធីនៃការដេញថ្លៃជាសាធារណៈ ។

នីតិវិធីសម្រាប់ការទទួលបានសិទ្ធិប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ នៅក្នុងដែនព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ២២.-

ផ្នែកណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលជាតំបន់មជ្ឈដ្ឋានពិសេសឬមានតម្លៃផ្នែកវិទ្យាសាស្ត្រ វប្បធម៌ ទេសចរណ៍ ឬជាតំបន់អភិរក្សជីវៈចម្រុះ ទឹកនិងដី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីដាក់ជាព្រៃការពារ ។

រាល់ការបង្កើត ឬការរំសាយព្រៃការពារត្រូវមានរបាយការណ៍ជូនរដ្ឋសភានិងព្រឹទ្ធសភា ។

មាត្រា ២៣.-

រដ្ឋបាលព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងព្រៃការពារនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលសម្រេចដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការអនុវត្តន៍ច្បាប់ព្រៃឈើ និងគ្រប់សកម្មភាពប្រតិបត្តិក្នុងការរៀបចំគ្រប់គ្រងការពារគ្រប់ដែនព្រៃការពារនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ ជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់ ។

ជំពូកទី ៧
វិធីលិខិតអនុញ្ញាត និងសិទ្ធិអំណាច

មាត្រា ២៤.-

ផល អនុផលព្រៃឈើទាំងអស់ដែលស្ថិតនៅក្នុង និងមានប្រភពចេញពីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាសម្បត្តិរដ្ឋ លើកលែងតែសិទ្ធិលើផល អនុផលព្រៃឈើដែលត្រូវ

បានប្រគល់ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ ដែលមានបំណងប្រមូលផល អនុផលព្រៃឈើ សម្រាប់គោលបំណងពាណិជ្ជកម្ម ត្រូវមានលិខិតអនុញ្ញាតប្រមូលផលព្រៃឈើចេញដោយរដ្ឋបាលព្រៃឈើ ។

ការប្រមូលផល អនុផលព្រៃឈើដោយសមាជិកសហគមន៍មូលដ្ឋានដែលមានបរិមាណស្មើ ឬក្រោមបរិមាណបំរើសេចក្តីត្រូវការសម្រាប់ការរស់នៅជាប្រពៃណី ដូចមានចែងក្នុងជំពូកទី ៩ នៃច្បាប់នេះ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតឡើយ ។

មាត្រា ២៥.-

រាល់សកម្មភាពលើសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងផល អនុផលព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជាតម្រូវឱ្យមានលិខិតអនុញ្ញាតសំខាន់ៗ ជាអាទិ៍ដូចខាងក្រោម :

១- លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

២- លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ ។

៣- លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ។

៤- លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ ។

៥- លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើ ។

៦- ប្រកាសស្តីពីការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ។

៧- លិខិតអនុញ្ញាតចូលព្រៃ ដើម្បីការងាររៀបចំព្រៃគុប ។

៨- លិខិតអនុញ្ញាតបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ ។

៩- លិខិតអនុញ្ញាតបង្កើតឡគ្រប់ប្រភេទ ដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ។

១០- លិខិតកំណត់កូតាអនុញ្ញាតឱ្យនាំចេញផល អនុផលព្រៃឈើ ។

១១- លិខិតអនុញ្ញាតនាំចេញ នាំចូលផល អនុផលព្រៃឈើ ។

១២- លិខិតអនុញ្ញាតផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

លិខិតអនុញ្ញាតដូចមានចែងខាងលើ ត្រូវបានផ្តល់សិទ្ធិស្នើសុំចំពោះ :

១- ព្រៃសម្បទានិកដែលបានទទួលការឯកភាពលើផែនការប្រមូលផល

អនុផលព្រៃឈើប្រចាំឆ្នាំ ដូចតម្រូវដោយកិច្ចព្រមព្រៀងព្រៃសម្បទាន ។

២- នីតិបុគ្គល ដែលបានទទួលការឯកភាពលើការប្រមូលផលក្នុងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ។

៣- សហគមន៍ដែលបានទទួលសិទ្ធិធ្វើការប្រមូលផលក្នុងព្រៃសហគមន៍ លើសពីកម្រិតប្រើប្រាស់ជាប្រពៃណី ក្រោមវិធានសហគមន៍ព្រៃឈើ ។

៤- បុគ្គល ឬអតិថិជន ដែលដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីតំបន់ព្រៃប្រមូលផលឆ្ពោះទៅទិសដៅកំណត់ ។

៥- រូបវន្តបុគ្គល នីតិបុគ្គល សហគមន៍ ឬអតិថិជនទូទៅដែលអាចទទួលសិទ្ធិស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

លិខិតអនុញ្ញាតក្រោមមាត្រានេះ ត្រូវសំគាល់ដោយ :

១- ឈ្មោះអ្នកកាន់លិខិតអនុញ្ញាត ។

២- រយៈពេលសុពលភាពនៃលិខិតអនុញ្ញាត ។

៣- ទីតាំង និងព្រំប្រទល់ជាក់លាក់នៃតំបន់ប្រមូលផល អនុផលព្រៃឈើ។

៤- បរិមាណផល អនុផលព្រៃឈើដែលបានអនុញ្ញាតគិតជាឯកតាកំណត់ដោយរដ្ឋបាលព្រៃឈើ ។

៥- ប្រភព និងទិសដៅនៃការដឹកជញ្ជូនផល អនុផលព្រៃឈើ ។

៦- ចំណុចផ្សេងទៀត អាស្រ័យតាមប្រភេទលិខិតអនុញ្ញាតដែលកំណត់ដោយរដ្ឋបាលព្រៃឈើ ។

លិខិតអនុញ្ញាតក្រោមមាត្រានេះអាចពន្យារពេលបន្តប្រើប្រាស់បាន ដោយផ្អែកលើរបាយការណ៍វាយតម្លៃពីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

គំរូឯកសារជាលាយលក្ខអក្សរសម្រាប់លិខិតអនុញ្ញាតនីមួយៗ ត្រូវកំណត់ជាផ្លូវការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ២៦.-

ការទទួលខុសត្រូវក្នុងការចេញលិខិតអនុញ្ញាតមានដូចតទៅ :

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិអំណាចសម្រេចលើ :

១- លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើសម្រាប់ព្រៃសម្បទាន និងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ។

២- កូតាអនុញ្ញាតឱ្យនាំចេញ និងនាំចូលផល អនុផលព្រៃឈើ យោងតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

៣- លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើ ដូចមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ ។

៤- ប្រកាសស្តីពីការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទធំ និងមធ្យម ។

ប្រធានរដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់ :

១- លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើសម្រាប់ព្រៃសម្បទាន និងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ។

២- លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីព្រៃសម្បទាន និងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ។

៣- លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ សម្រាប់នាំចេញនាំចូល ។

៤- លិខិតអនុញ្ញាតចូលព្រៃដើម្បីដំណើរការរៀបចំព្រៃគុបមុនពេលចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៥- លិខិតអនុញ្ញាត ឬចុះទិដ្ឋាការលើអាជ្ញាប័ណ្ណនាំចេញនាំចូលផល អនុផលព្រៃឈើ ។

នាយខណ្ឌរដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់ :

១- លិខិតកំណត់កូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើសម្រាប់សហគមន៍មូលដ្ឋាន ។

២- លិខិតអនុញ្ញាតឱ្យបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ។

៣- លិខិតអនុញ្ញាតឱ្យបង្កើតឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមមានលក្ខណៈឧស្សាហកម្ម ឬសិប្បកម្ម ។

៤- លិខិតអនុញ្ញាតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីព្រៃសហគមន៍ ។

នាយផ្នែករដ្ឋបាលព្រៃឈើមានសិទ្ធិអំណាចផ្តល់ :

១- លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើលើបរិមាណលើសពីសិទ្ធិប្រើប្រាស់ជាប្រពៃណី សម្រាប់សហគមន៍មូលដ្ឋានក្នុងព្រៃសហគមន៍ ។

២- រាល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើដែលមានប្រភពចេញពីតំបន់ដែនសមត្ថកិច្ចរបស់ផ្នែករដ្ឋបាលព្រៃឈើនោះ ។

មាត្រា ២៧.-

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិអំណាចចេញលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើដល់រូបវន្តបុគ្គល នីតិបុគ្គល សម្រាប់ដំណើរការសកម្មភាពនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចខាងក្រោម ៖

១- ការសិក្សាស្រាវជ្រាវបច្ចេកទេស និងវិទ្យាសាស្ត្រ ។

២- ការអប់រំ និងការបណ្តុះបណ្តាលវិស័យកសិកម្ម ។

៣- ការប្រើប្រាស់ធនធានទឹកសម្រាប់ប្រព័ន្ធស្រោចស្រព ឬគោលបំណងកសិកម្ម ដោយមានការឯកភាពពីក្រសួងធនធានទឹក និងឧតុនិយម ។

៤- ការបង្កើតសួនរុក្ខជាតិតាមសាស្ត្រ ឬស្ថានីយ៍ពិសោធន៍ ។

៥- ការបង្កើតថ្នាលកូនឈើត្រូវផ្ទេរ ។

៦- ការបង្កើតតំបន់សម្រាប់សម្រាកលំហែ ទស្សនាចរកំសាន្ត ឬការថែរក្សាភាពយន្តឯកសារ ។

លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើនេះមិនត្រូវយកទៅប្រើដើម្បីប្រមូលផល អនុផលព្រៃឈើពីតំបន់ដែលបានកំណត់សម្រាប់សកម្មភាពខាងលើឡើយ លើកលែងតែការដកហូតសម្រាប់គោលបំណងស្រាវជ្រាវរុក្ខវប្បកម្ម ដើម្បីបង្កើនគុណភាពព្រៃឈើ ។

ជំពូកទី ៨

ការហាមឃាត់ការប្រមូលផល អនុផលព្រៃឈើ និងការការពារព្រៃឈើ

មាត្រា ២៨.-

រាល់ការផ្តល់ ឬបែងចែកព្រៃបម្រុងទុកអចិន្ត្រៃយ៍សម្រាប់ការប្រមូលផល អនុផលព្រៃឈើ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ អាចប្រព្រឹត្តទៅបានតែក្នុងករណីព្រៃបម្រុងទុកអចិន្ត្រៃយ៍នោះជាប្រភេទព្រៃផ្តល់ផល និងមានសក្តានុពលផ្តល់ផលដែលការគ្រប់គ្រង និងត្រួតពិនិត្យត្រូវតែអនុវត្តតាមក្រមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា ។

គ្មានបុគ្គលណាមានសិទ្ធិផ្តល់លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនព្រៃការពារគ្រប់ប្រភេទនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ឡើយ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចស្នើសុំរាជរដ្ឋាភិបាលកែប្រែដែនព្រៃការពារទៅជាដែនព្រៃផ្តល់ផល នៅពេលដែលរដ្ឋបាលព្រៃឈើបានផ្តល់ទិន្នន័យសិក្សាថ្មីចំពោះព្រៃការពារណាមួយ ដែលអាចមានសក្តានុពលគ្រប់គ្រាន់សម្រាប់ផលហូត បើពុំនោះទេការប្រមូលផល អនុផលព្រៃឈើត្រូវហាមឃាត់ ។

មាត្រា ២៩.-

លើកលែងតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមូលហេតុជាអាទិ៍ លក្ខខណ្ឌអាកាសធាតុមិនអំណោយផល ឈើចំណីផ្លូវដែលត្រូវសាងសង់ដោយមានការអនុញ្ញាត ឬលក្ខខណ្ឌឧបទ្ទវហេតុផ្សេងទៀត ដែលស្នើឡើងដោយរដ្ឋបាលព្រៃឈើ ការប្រមូលផល អនុផលព្រៃឈើដូចខាងក្រោមក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ :

១- ប្រភេទឈើជាប់ក្នុងលំដាប់ថ្នាក់ ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ ។

២- ប្រភេទឈើដែលមានដោយកម្រ ។

៣- ប្រភេទឈើដែលប្រជាជនមូលដ្ឋានចោះយកជ័រតាមប្រពៃណី ។

៤- ដើមឈើផ្តល់ជ័រមានតម្លៃ ។

ផល អនុផលព្រៃឈើដែលហាមឃាត់ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ៣០.-

ហាមឃាត់ការកែច្នៃផល អនុផលព្រៃឈើ ឬការបង្កើត និងដំណើរការមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ រោងចក្រកែច្នៃឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ និងឡគ្រប់ប្រភេទនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

គ្រប់មូលដ្ឋានកែច្នៃផល អនុផលព្រៃឈើ និងឡគ្រប់ប្រភេទ ត្រូវមានទីតាំងស្ថិតនៅចំងាយប្រាំ (៥)គីឡូម៉ែត្រយ៉ាងតិច ពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចធ្វើការលើកលែងការហាមឃាត់ដែលចែងក្នុងកថាខ័ណ្ឌទី ២ នៃមាត្រានេះ ក្នុងករណីដែលរដ្ឋបាលព្រៃឈើសិក្សាឃើញថា

ផលប្រយោជន៍នៃការលើកលែងនេះមិនមានផលប៉ះពាល់សង្គម បរិស្ថាន ឬមានផលប៉ះពាល់កម្រិតទាប ។

មាត្រា ៣១.-

ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវសាធារណៈ ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការឈូសឆាយដីព្រៃក្នុងគោលបំណងស្ថាបនាផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែមានការសម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

រាល់គំរោងស្ថាបនាផ្លូវសាធារណៈ ឬផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ស្របតាមមាត្រា ៤ នៃច្បាប់នេះ ។

ការដាក់តាំងលំនៅដ្ឋានថ្មីតាមដងផ្លូវសាធារណៈ ឬផ្លូវព្រៃក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់លើកលែងតែមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

មាត្រា ៣២.-

ព្រៃឈើត្រូវបានការពារប្រឆាំងនឹងរាល់សកម្មភាពដែលធ្វើឱ្យខូចខាតបណ្តាលមកពីការធ្វើអាជីវកម្មហួសហេតុ ការកាប់រានដីព្រៃដោយវិលោភ ការបំពុលមជ្ឈដ្ឋានព្រៃឈើ ភ្លើងឆេះព្រៃ ការធ្វើចំការពនេចរ ជម្ងឺ សត្វល្អិតចង្រៃ និងការនាំចូលប្រភេទរុក្ខជាតិ និងសត្វរាតត្បាត ។

សកម្មភាពដែលនាំឱ្យខូចខាតដល់ព្រៃឈើដែលត្រូវបានហាមឃាត់មានដូចជា :

១- រំកិល ដកចេញ ឬបំផ្លាញគោលសីមា ឬសញ្ញាសំគាល់សម្រាប់កំណត់ដែនព្រៃឈើ ។

២- គៀរ បំពុល កាប់បំផ្លាញ ឆ្លូតរំលំដើមឈើ ឬឆោសរំលើងគល់ឈើដោយគ្មានការចាំបាច់ខាងបច្ចេកទេស ។

៣- ប្រើសិទ្ធិប្រមូលផល អនុផលព្រៃឈើខុសពីសិទ្ធិ ដែលត្រូវបានទទួលស្គាល់ ឬអនុញ្ញាត ។

៤- ប្រើប្រាស់មធ្យោបាយផ្សេងៗ លែង ឬចងសត្វពាហនៈក្នុងកន្លែងដែលមានកូនឈើដុះថ្មីក្រោយពេលអាជីវកម្ម ឬភ្លើងព្រៃ ឬក្នុងតំបន់ព្រៃកំពុងតែដាំ ឬទើបនឹងដាំ ។

៥- បង្កើតមូលដ្ឋានកែច្នៃវល្លិ៍ផ្សេងទៀត ឬអនុផលព្រៃឈើផ្សេងទៀតដែលនាំមកនូវការបំពុល ឬបំផ្លាញមជ្ឈដ្ឋានព្រៃឈើ ។

មាត្រា ៣៣.-

រាល់សកម្មភាពកាប់រានដីព្រៃក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែករណីដែលមានចែងក្នុងមាត្រា ៣១ មាត្រា ៣៥ និងមាត្រា ៣៧ នៃច្បាប់នេះ ។

មាត្រា ៣៤.-

ការនាំចេញ នាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬប្រភេទរុក្ខជាតិព្រៃត្រូវឆ្លងកាត់ការសិក្សាស្រាវជ្រាវ វាយតម្លៃពីរដ្ឋបាលព្រៃឈើ និងត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការនាំចូលគ្រាប់ពូជរុក្ខជាតិព្រៃគ្រប់ប្រភេទ ត្រូវមានវិញ្ញាបនបត្រគ្រាប់ពូជ ដែលបញ្ជាក់ដោយអាជ្ញាធរវិទ្យាសាស្ត្ររបស់ប្រទេសនាំចេញ ។

មាត្រា ៣៥.-

បន្ថែមលើច្បាប់ដទៃទៀតដែលពាក់ព័ន្ធនឹងការយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀត ដែលត្រូវអនុវត្តក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការសិក្សាវាយតម្លៃជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលដោយត្រូវអនុវត្តតាមមាត្រា ៤ នៃច្បាប់នេះ ។

ការអនុញ្ញាតនេះត្រូវកម្រិតផងដែរនូវវិធានការការពារ និងស្តារឡើងវិញនៅទីកន្លែងគាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀត ដែលអ្នកទទួលសិទ្ធិត្រូវទទួលបន្ទុកដើម្បី :

១- ចៀសវាងបង្ក ឬធ្វើឱ្យធ្ងន់ធ្ងរដល់ការហូរច្រោះបាក់ដី ឬធ្វើឱ្យខូចខាតដល់ការលូតលាស់របស់រុក្ខជាតិ ឬធ្វើឱ្យខូចខាតដល់ប្រព័ន្ធជលសាស្ត្រ និងគុណភាពទឹក ។

២- រៀបចំស្តារទីតាំងនោះឱ្យមានសភាពដូចដើមវិញ ក្រោយពេលបញ្ចប់កិច្ចការគាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ និងធនធានធម្មជាតិដទៃទៀត ក្នុងរយៈពេលដែល

លិខិតអនុញ្ញាតបានកំណត់ ។

មាត្រា ៣៦.-

ហាមបង្កភ្លើងឆេះព្រៃក្នុងដែនសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។ ការប្រើប្រាស់ភ្លើងអាចអនុគ្រោះចំពោះរដ្ឋបាលព្រៃឈើ ដើម្បីផលប្រយោជន៍វុក្ខវប្បកម្ម ឬអនាម័យព្រៃ ។

គោលការណ៍ណែនាំក្នុងការកំណត់តំបន់ត្រួតពិនិត្យភ្លើងឆេះព្រៃ ការការពារភ្លើងឆេះព្រៃ និងការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងភ្លើងឆេះព្រៃ សម្រាប់ជាវិធានការអនុវត្តគ្រប់តំបន់ព្រៃឈើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធនិងអាជ្ញាធរដែនដីគ្រប់ថ្នាក់ ត្រូវមានករណីយកិច្ចទទួលខុសត្រូវ ថែរក្សា ការពារព្រៃឈើ បង្ការ និងប្រយុទ្ធនឹងភ្លើងឆេះព្រៃ ។

មាត្រា ៣៧.-

សហគមន៍មូលដ្ឋានដែលប្រកបរបរចំការពនេចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជិការួចហើយជាមួយរដ្ឋ ។ ផ្នែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាននេះ ត្រូវផ្តល់ការអនុញ្ញាតការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះ ដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសហគមន៍នោះ ។ ការអនុវត្តន៍ចំការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃធម្មជាតិមិនទាន់ប៉ះពាល់ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

ដីព្រៃឈើដែលរៀបចំបម្រុងសម្រាប់ចំការពនេចរ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៣៨.-

ការអារច្រៀក និងការចាំងឈើមូលនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ ។

ការប្រើប្រាស់រណារយន្តជាមធ្យោបាយប្រមូលផលព្រៃឈើនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបានហាមឃាត់ លើកលែងតែមានលិខិតអនុញ្ញាតប្រើប្រាស់ចេញដោយរដ្ឋបាលព្រៃឈើ ។

មាត្រា ៣៩.-

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឱ្យកាប់ដើមឈើ រានដីព្រៃឈើ ឬធ្វើសកម្មភាពគ្រប់យ៉ាង

ដើម្បីប្រមូលផល អនុផលព្រៃឈើ ឬកាន់កាប់ដីក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះឡើយ ។

ជំពូកទី ៩
សិទ្ធិប្រើប្រាស់ជាប្រពៃណី ការគ្រប់គ្រងព្រៃសហគមន៍និងព្រៃឯកជន

មាត្រា ៤០.-

ចំពោះសហគមន៍មូលដ្ឋានរស់នៅក្នុង ឬក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ រដ្ឋត្រូវទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាននោះសម្រាប់គោលបំណងទំនៀមទំលាប់ ជំនឿ សាសនា និងការរស់នៅ ដូចមានចែងក្នុងមាត្រានេះ ។

សិទ្ធិប្រើប្រាស់ជាប្រពៃណីលើផល អនុផលព្រៃឈើដោយសហគមន៍មូលដ្ឋានមិនតម្រូវឱ្យមានលិខិតអនុញ្ញាតប្រមូលផលឡើយ ។ សិទ្ធិប្រើប្រាស់ជាប្រពៃណីក្រោមមាត្រានេះរួមមាន :

១- ការរើសប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការរុករកឃ្មុំ ការចោះយកជ័រ និងរុករកអនុផលព្រៃឈើដទៃទៀតទាំងអស់ ។

២- ការប្រើប្រាស់ឈើមកសង់លំនៅដ្ឋាន ក្រោលសត្វ របងនិងសម្រាប់ធ្វើឧបករណ៍កសិកម្ម ។

៣- ការច្រូតយកស្មៅ ឬលែងសត្វពាហនៈឱ្យស៊ីស្មៅក្នុងព្រៃ ។

៤- ការប្រើប្រាស់ផល អនុផលព្រៃឈើផ្សេងទៀតស្របតាមការប្រើប្រាស់ជាប្រពៃណី ជាលក្ខណៈគ្រួសារ ។

៥- សិទ្ធិដោះដូរ ឬលក់អនុផលព្រៃឈើដោយពុំចាំបាច់មានលិខិតអនុញ្ញាតប្រសិនបើការលក់ដូរនេះមិនគំរាមកំហែងដល់និរន្តរភាពនៃព្រៃឈើ ។ អតិថិជន ឬភាគីទីបីណាមួយដែលបានប្រមូលទិញអនុផលព្រៃឈើទាំងនោះពីសហគមន៍មូលដ្ឋានក្នុងគោលដៅពាណិជ្ជកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ អាចធ្វើការដឹកជញ្ជូនទៅកាន់ទិសដៅបានដោយតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូន ក្រោយពេលបានបង់ថ្លៃសួយសារនិងបុព្វលាភលើអនុផលព្រៃឈើទាំងនោះរួច ។

សហគមន៍មូលដ្ឋានមិនអាចផ្ទេរសិទ្ធិប្រើប្រាស់ជាប្រពៃណីឱ្យទៅភាគីទីបីបានឡើយ

ទោះបីជាមានកិច្ចព្រមព្រៀងទៅវិញទៅមកក្តី ឬស្ថិតក្រោមកិច្ចសន្យាក្តី ។ សិទ្ធិប្រើប្រាស់ជាប្រពៃណីត្រូវ :

១- ស្របតាមលំនឹងធម្មជាតិ មាននិរន្តរភាពចំពោះធនធានព្រៃឈើ និងគោរពសិទ្ធិអ្នកដទៃ ។

២- ស្របតាមការអនុញ្ញាត និងការហាមឃាត់ ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៤១.-

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិប្រគល់ផ្នែកណាមួយនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ឱ្យទៅសហគមន៍ដែលរស់នៅក្នុង ឬជិតតំបន់ព្រៃឈើ ក្រោមរូបភាពជាព្រៃសហគមន៍ ។

មាត្រា ៤២.-

ខ័ណ្ឌរដ្ឋបាលព្រៃឈើ តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត មានភារកិច្ចសិក្សារៀបចំព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដើម្បីបង្កើតជាព្រៃសហគមន៍ ដោយកំណត់ព្រំប្រទល់ច្បាស់លាស់ និងមានទំហំសមស្របផ្អែកតាមលទ្ធភាពធនធានព្រៃឈើ និងតម្រូវការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍ ។

នាយខ័ណ្ឌរដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ជាមួយសហគមន៍មូលដ្ឋានណាមួយដែលរស់នៅក្នុង ឬក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។ កិច្ចព្រមព្រៀងនេះ ត្រូវមានសុពលភាពមិនលើសពីរយៈពេលដប់ប្រាំ (១៥)ឆ្នាំ តែអាចពន្យារបានដោយផ្អែកលើរបាយការណ៍ពិនិត្យ និងវាយតម្លៃឡើងវិញរបស់ថ្នាក់ផ្នែករដ្ឋបាលព្រៃឈើ ។

មាត្រា ៤៣.-

ព្រៃសហគមន៍ត្រូវបានគ្រប់គ្រងក្នុងលក្ខណៈសេដ្ឋកិច្ច និងដោយធានានិរន្តរភាពដោយសហគមន៍មូលដ្ឋាន ស្របតាមផែនការគ្រប់គ្រងព្រៃសហគមន៍ វិធានសហគមន៍ព្រៃឈើ និងគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។ រដ្ឋបាលព្រៃឈើត្រូវផ្តល់ជំនួយបច្ចេកទេសតាមការស្នើសុំរបស់សហគមន៍មូលដ្ឋាន និងត្រូវតាមដានត្រួតពិនិត្យការអនុវត្តន៍ផែនការគ្រប់គ្រងព្រៃសហគមន៍ ។

ផែនការគ្រប់គ្រងព្រៃសហគមន៍ត្រូវរៀបចំដោយសហគមន៍មូលដ្ឋាន និងមានការយល់ព្រមដោយថ្នាក់ខ័ណ្ឌរដ្ឋបាលព្រៃឈើ ។ ផែនការនេះនឹងត្រូវផ្ញើជូនទៅថ្នាក់កណ្ដាលរដ្ឋបាលព្រៃឈើ និងត្រូវពិនិត្យឡើងវិញជារៀងរាល់ប្រាំ (៥)ឆ្នាំម្ដង ឬមុនពេលកំណត់ក្នុងករណីចាំបាច់ ។

ទោះបីព្រៃសហគមន៍ត្រូវបានដាំដុះ ឬដុះដោយធម្មជាតិក៏ដោយ ក៏ការគ្រប់គ្រងត្រូវអនុវត្តតាមផែនការគ្រប់គ្រងព្រៃសហគមន៍ និងក្រោមការឧបត្ថម្ភបច្ចេកទេសនិងត្រួតពិនិត្យបច្ចេកទេសដោយរដ្ឋបាលព្រៃឈើ ។

វិធានសម្រាប់ការបង្កើត ការគ្រប់គ្រង និងការប្រើប្រាស់ព្រៃសហគមន៍ ត្រូវកំណត់ដោយអនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ ។

គោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ៤៤.-

សហគមន៍មូលដ្ឋានដែលដំណើរការក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ មានសិទ្ធិប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនព្រៃឈើស្របតាមផែនការគ្រប់គ្រងព្រៃសហគមន៍ដែលបានកំណត់ព្រំប្រទល់ជូន ដូចមានចែងក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍ ។

សហគមន៍មូលដ្ឋានមិនអាចយកព្រៃសហគមន៍ទៅប្រើប្រាស់ក្រោមរូបភាពជាព្រៃសម្បទាន ឬលក់ ដូរ ឬផ្ទេរសិទ្ធិលើព្រៃឈើនោះឱ្យភាគីទីបីបានឡើយ ។

មាត្រា ៤៥.-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវទទួលស្គាល់ព្រៃពាក់ព័ន្ធជំនឿសាសនារបស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុង ឬក្បែរព្រៃនោះ ទុកជាព្រៃការពារសម្រាប់គោលបំណងសាសនា វប្បធម៌ ឬការអភិរក្ស ។ ដើមឈើជំនឿសាសនាអាចត្រូវបានដៅសម្គាល់ជាពិសេសមិនអនុញ្ញាតឱ្យកាប់រំលំ និងត្រូវកំណត់ក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍ ។

មាត្រា ៤៦.-

បុគ្គលដែលបានដាំដើមឈើលើដីកម្មសិទ្ធិឯកជនផ្ទាល់ ឬលើដីព្រៃរបស់រដ្ឋដែលបានប្រគល់សិទ្ធិប្រើប្រាស់ មានសិទ្ធិថែរក្សា អភិវឌ្ឍ ប្រើប្រាស់ លក់និងចែកចាយផលិតផលរបស់ខ្លួនបាន ។

វិធានស្តីពីព្រៃឯកជនត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីជំរុញលើកទឹកចិត្តដល់បុគ្គលក្នុងការដាំដុះនិងថែទាំចំការព្រៃឈើ ។

មាត្រា ៤៧.-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចផ្តល់ជូនបុគ្គល និងសហគមន៍ដែលអនុវត្តការគ្រប់គ្រងព្រៃឈើ ឬដាំដើមឈើដែលសម្រេចបាននូវបរិមាណនិងគុណភាពខ្ពស់ នូវប្រព័ន្ធលើកទឹកចិត្តទៅតាមវិធានមានជាអាទិ៍ :

១- ប្រគល់លិខិតសរសើរ ប័ណ្ណសរសើរនិងប្រគល់គ្រឿងឥស្សរិយយស។
២- ផ្តល់ជំនួយអភិវឌ្ឍន៍ដោយផ្ទាល់ក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិ។
៣- ពន្យាររយៈពេលកិច្ចព្រមព្រៀងសំរាប់ព្រៃសហគមន៍ ។
៤- ផ្សព្វផ្សាយពីសកម្មភាពមានស្នាដៃ ។

ជំពូកទី ១០
ការអភិរក្សសត្វព្រៃ

មាត្រា ៤៨.-

ពពួកសត្វព្រៃគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺជាសម្បត្តិរបស់រដ្ឋ និងជាសមាសភាគនៃធនធានព្រៃឈើដែលរួមមាន : ពួកថនិកសត្វ បក្សីសត្វ ឧរង្គសត្វ ថលជលិកសត្វ បាណកសត្វ និងសត្វឥតឆ្អឹងកងផ្សេងទៀតព្រមទាំងពង កូនរបស់វា ។ ពពួកសត្វព្រៃទាំងអស់នេះស្ថិតនៅក្រោមការគ្រប់គ្រងការសិក្សាស្រាវជ្រាវនិងការអភិរក្សដោយរដ្ឋបាលព្រៃឈើ ដោយមិនរាប់បញ្ចូលត្រី និងសត្វបង្កកំណើតក្នុងទឹក ។

សំណាកសត្វព្រៃគឺជាសត្វព្រៃដែលស្លាប់ ទោះជានៅខ្លួនទាំងមូល សរីរាង្គក្នុង សរីរាង្គក្រៅ បំណែកឆ្អឹង ឬផលិតផលកែច្នៃ ត្រូវស្ថិតក្រោមសិទ្ធិគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ ។

គ្រប់ប្រភេទសត្វព្រៃទាំងអស់ ត្រូវបានបែងចែកជាបីក្រុមគឺ :

១- ក្រុមប្រភេទជិតផុតពូជ ។
២- ក្រុមប្រភេទមានដោយកម្រ ។
៣- ក្រុមប្រភេទមានដោយបង្គួរ ។

លក្ខណៈវិនិច្ឆ័យសម្រាប់ចាត់ថ្នាក់ក្រុមនីមួយៗ និងបញ្ជីឈ្មោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជ និងប្រភេទមានដោយកម្រដែលអាចប្រែប្រួលទៅតាមតំបន់ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់រដ្ឋបាលព្រៃឈើ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថាន ។

មាត្រា ៤៩.-

ហាមឃាត់ដាច់ខាតរាល់សកម្មភាពបរបាញ់ យាយីបំផ្លិចបំផ្លាញសត្វព្រៃគ្រប់ប្រភេទដោយ :

១- ការប្រើប្រាស់មធ្យោបាយបង្កគ្រោះថ្នាក់គ្រប់ប្រភេទ ។

២- ការប្រមាញ់ក្នុងរដូវកាលហាមឃាត់ ។

៣- ការប្រមាញ់ក្នុងតំបន់ការពារ និងទីសាធារណៈពិសេស ។

ដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិតអនុញ្ញាតចំពោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជនិងក្រុមប្រភេទមានដោយកម្រ សម្រាប់គោលបំណងដូចខាងក្រោម :

១- ការសិក្សាអប់រំ ឬការស្រាវជ្រាវវិទ្យាសាស្ត្រ ។

២- ការគាំទ្រដល់កម្មវិធីនៃការចាប់បង្កាត់ពូជ ។

៣- ការផ្លាស់ប្តូរប្រភេទសត្វ អនុលោមតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការអន្តរជាតិ ។

រាល់ការធ្វើសកម្មភាពដូចខាងក្រោម ចំពោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជ និងក្រុមប្រភេទមានដោយកម្រ ត្រូវហាមឃាត់ :

១- ការយាយី ឬបំផ្លិចបំផ្លាញដល់ប្រភេទសត្វខាងលើ និងជម្រករបស់ប្រភេទសត្វទាំងនេះ ។

២- ការបរបាញ់ ទាក់ចាប់ ដាក់អន្ទាក់ បំពុល ។

៣- ការយកធ្វើជាកម្មសិទ្ធិ សន្និធិ ឬថែរក្សាជាលក្ខណៈសួនសត្វ ឬគ្រួសារ។

៤- ការដឹកជញ្ជូន ។

៥- ការធ្វើពាណិជ្ជកម្ម ។

៦- ការនាំចេញ នាំចូល ។

វិធាននៃការធ្វើសកម្មភាពចំពោះសត្វព្រៃគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ។

មាត្រា ៥០.-

រាល់ការធ្វើសកម្មភាពដូចខាងក្រោម ចំពោះប្រភេទសត្វក្នុងក្រុមប្រភេទមានដោយបង្ករ ត្រូវហាមឃាត់លើកលែងតែមានលិខិតអនុញ្ញាតចេញដោយរដ្ឋបាលព្រៃឈើ :

១- ការធ្វើសន្និធិ ការថែរក្សាជាលក្ខណៈសួនសត្វ ឬគ្រួសារ ។

២- ការដឹកជញ្ជូន និងធ្វើពាណិជ្ជកម្មលើសពីបរិមាណចាំបាច់សម្រាប់ការប្រើប្រាស់ជាប្រពៃណី ។

ការនាំចេញ នាំចូលប្រភេទសត្វព្រៃក្នុងក្រុមប្រភេទមានដោយបង្ករ ត្រូវមានលិខិតអនុញ្ញាត ចេញដោយរដ្ឋបាលព្រៃឈើដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ៥១.-

រដ្ឋបាលព្រៃឈើត្រូវប្រមូលប្រាក់ចំណូលអភិរក្សសត្វព្រៃនិងប្រាក់សួយសារសត្វព្រៃដូចខាងក្រោម :

១- ប្រាក់ចំណូលអភិរក្សសត្វព្រៃត្រូវបង់ចូលមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ។

២- ប្រាក់សួយសារសត្វព្រៃ ត្រូវបង់ចូលថវិកាជាតិ ។

ប្រាក់ចំណូលអភិរក្សសត្វព្រៃ និងប្រាក់សួយសារសត្វព្រៃត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ១១
ថ្លៃសួយសារ និងបុព្វលាភ លើផល អនុផលព្រៃឈើ

មាត្រា ៥២.-

លើកលែងតែករណីដូចមានចែងក្នុងមាត្រា ៥៣ នៃច្បាប់នេះ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រមូលផល អនុផលព្រៃឈើសម្រាប់គោលដៅពាណិជ្ជកម្មលើព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវបង់ថ្លៃសួយសារនិងបុព្វលាភចូលថវិកាជាតិតាមរយៈរដ្ឋបាលព្រៃឈើ ។

រាជរដ្ឋាភិបាលត្រូវកំណត់ថ្លៃសួយសារនិងបុព្វលាភ ផ្អែកតាមសំណើរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រដ្ឋមិនតម្រូវឱ្យបង់ថ្លៃសួយសារនិងបុព្វលាភ សម្រាប់ការប្រមូលផល អនុផលព្រៃឈើលើព្រៃឯកជនឡើយ ។

គំរូកិច្ចព្រមព្រៀងព្រៃសម្បទាន ត្រូវបញ្ចូលនូវតារាងនៃថ្លៃសួយសារនិងបុព្វលាភលើផល អនុផលព្រៃឈើ ។

មាត្រា ៥៣.-

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចបន្ថយ ឬមិនយកថ្លៃសួយសារនិងបុព្វលាភលើផល អនុផលព្រៃឈើ ដែលប្រមូលពីព្រៃឈើរដ្ឋសម្រាប់គោលបំណងវិទ្យាសាស្ត្រ ឬដើម្បីបង្កើនការលើកទឹកចិត្តសេដ្ឋកិច្ច ចំពោះការប្រើប្រាស់អស់លទ្ធភាពលើផលិតផល ។

រដ្ឋមិនយកថ្លៃសួយសារ និងបុព្វលាភពីសហគមន៍មូលដ្ឋានលើផល អនុផលព្រៃឈើដែលប្រមូលដោយសហគមន៍មូលដ្ឋានសម្រាប់សិទ្ធិប្រើប្រាស់ជាប្រពៃណី ឬប្រមូលពីព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ឡើយ ។

មាត្រា ៥៤.-

រាល់ផល អនុផលព្រៃឈើត្រូវវាយតម្លៃដោយមន្ត្រីរដ្ឋបាលព្រៃឈើលើបរិមាណនិងគុណភាពនៅគិនរក្នុងព្រៃគុបប្រចាំឆ្នាំ មុនពេលដឹកចេញពីព្រៃ ។

គុណភាព និងបរិមាណនៃផល អនុផលព្រៃឈើដែលបានវាយតម្លៃរួច ត្រូវចុះក្នុងកំណត់ហេតុបញ្ជីសៀវភៅ ក ដោយមានការឯកភាពពីប្រធានរដ្ឋបាលព្រៃឈើ ។

មាត្រា ៥៥.-

រាល់ផល អនុផលព្រៃឈើដែលបានចុះក្នុងកំណត់ហេតុបញ្ជីសៀវភៅ ក ត្រូវបង់ប្រាក់ថ្លៃសួយសារនិងបុព្វលាភ ។

វិធាននៃការបង់ និងទទួលប្រាក់ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៥៦.-

អ្នកកាន់កាប់លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើមិនអាចផ្ទេរ ឬលក់សិទ្ធិលើផល អនុផលព្រៃឈើទៅឱ្យបុគ្គលណាមួយផ្សេងទៀតបានឡើយ លុះត្រាតែខ្លួនបានបង់ថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើនោះរួច ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចសម្រេចឱ្យមានការពន្យារពេលការបង់ថ្លៃសួយសារ និងបុព្វលាភលើផល អនុផលព្រៃឈើចំពោះអ្នកកាន់កាប់លិខិត អនុញ្ញាតដែលបានទទួលស្គាល់ដោយរដ្ឋបាលព្រៃឈើ ថាបានអនុវត្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។ ការពន្យារនេះត្រូវផ្អែកតាមវិធាន និងគោលការណ៍ណែនាំស្របតាមមាត្រា ៥៥ កឋាខ័ណ្ឌទី ២ នៃច្បាប់នេះ ។

មាត្រា ៥៧.-

ប្រសិនបើអ្នកកាន់កាប់លិខិតអនុញ្ញាតមិនបានបង់ថ្លៃសួយសារ និងបុព្វលាភតាមកម្មវិធី ពេលវេលាកំណត់ទេនោះ រដ្ឋបាលព្រៃឈើមានសិទ្ធិដកហូតយកផល អនុផលព្រៃឈើទាំងនោះដោយគ្មានលក្ខខណ្ឌ និងឃាត់ទុកផល អនុផលព្រៃឈើ ទាំងនោះរក្សាជាកម្មសិទ្ធិរបស់រដ្ឋដដែល រហូតដល់មានដំណោះស្រាយវិវាទនេះតាមផ្លូវច្បាប់ ។

មាត្រា ៥៨.-

មុនពេលចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ អ្នកស្នើសុំលិខិតអនុញ្ញាតនោះត្រូវបង់ប្រាក់តំកល់ដើម្បីធានាការបង់ថ្លៃសួយសារ និងបុព្វលាភចូលថវិកាជាតិ ។ ហិរញ្ញប្រាក់តំកល់ត្រូវកំណត់ក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន ឬក្នុងលិខិតកំណត់ភូតាអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

ការប្រមូលផល អនុផលព្រៃឈើលើព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ មិនតម្រូវឱ្យមានការបង់ប្រាក់តំកល់នោះឡើយ ។

ជំពូកទី ១២
ការដាំដើមឈើឡើងវិញ និងមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ

មាត្រា ៥៩.-

ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់មានករណីយកិច្ចចូលរួមដាំដើមឈើ និងដាំដើមឈើឡើងវិញ ។

ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការដាំដើមឈើ និងដាំដើមឈើឡើងវិញ ត្រូវបានលើកទឹកចិត្តដោយរាជរដ្ឋាភិបាល តាមរយៈចលនារបស់សហគមន៍ និងអង្គការសង្គមផ្សេងៗទៀត ។

រដ្ឋបាលព្រៃឈើត្រូវមានវិធានការសមស្របក្នុងការអភិវឌ្ឍន៍ព្រៃឈើតាមរយៈការផ្សព្វផ្សាយ ការអប់រំ ការបំផុស ដល់បុគ្គលសហគមន៍ និងមហាជនឱ្យដាំដើមឈើ និងការពារព្រៃឈើ ដោយផ្តល់នូវជំនួយការបច្ចេកទេសចាំបាច់ ។

មាត្រា ៦០.-

ដើម្បីជំរុញការអប់រំប្រជាពលរដ្ឋឱ្យយល់ពីសារៈសំខាន់ និងផលប្រយោជន៍នៃព្រៃឈើ ទិវាពលកម្មដាំដើមឈើជាប្រពៃណីជាតិ ហៅថា **វុក្ខទិវា** ត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃទី ៩ ខែកក្កដា ជារៀងរាល់ឆ្នាំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឬព្រះរាជតំណាង ។

ប្រជាពលរដ្ឋទាំងពីរភេទដែលជាគូស្រករថ្មី ត្រូវបានលើកទឹកចិត្តដាំដើមឈើពីរដើមក្រោមកិច្ចសម្របសម្រួលនិងផ្តល់កូនឈើដោយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

រាជរដ្ឋាភិបាលត្រូវកំណត់សួនសម្រាប់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ និងអន្តរជាតិដាំដើមឈើដើម្បីទុកជាអនុស្សាវរីយ៍ ។

មាត្រា ៦១.-

ការដាំដើមឈើនៅលើដីព្រៃរបស់រដ្ឋ អាចធ្វើឡើងដោយរដ្ឋបាលព្រៃឈើផ្ទាល់ សហគមន៍ព្រៃឈើ ឬដោយមានការចូលរួមពីប្រជាពលរដ្ឋតាមរយៈការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋ ។

ការដាំដើមឈើនៅលើដីកម្មសិទ្ធិឯកជនអាចធ្វើឡើងបាន ដោយសិទ្ធិវន្តស្របតាមវិធានព្រៃឯកជន ដូចមានចែងក្នុងមាត្រា ៤៦ នៃច្បាប់នេះ ។

វិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសំរាប់ការដាំឈើ ត្រូវកំណត់ដោយអនុក្រឹត្យ ។ វិធាន និងបទបញ្ជាទាំងនេះត្រូវគិតពីសក្តានុពល ហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមនៃប្រភេទឈើ ដែលត្រូវជ្រើសរើសសំរាប់ការដាំនោះ ។

មាត្រា ៦២.-

រាជរដ្ឋាភិបាលត្រូវបង្កើតមូលនិធិមួយហៅថា **មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ** គ្រប់គ្រងចាត់ចែងនិងទទួលខុសត្រូវដោយគណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិដែលមានរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសហប្រធាន ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៦៣.-

មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិមានប្រភពចំណូលមកពី :

១- វិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ។

២- បុព្វលាភលើផល អនុផលព្រៃឈើ ។

៣- ប្រាក់ចំណូលអភិរក្សសត្វព្រៃ ។

៤- ជំនួយរបស់អង្គការអន្តរជាតិនានា ។

៥- អំណោយពីសប្បុរសជន និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ។

៦- កំរៃសេវាផ្សេងៗពីវិស័យព្រៃឈើ ។

រាល់ចំណូលខាងលើ ត្រូវបញ្ចូលក្នុងគណនីមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ។

មាត្រា ៦៤.-

មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិមិនអាចត្រូវយកទៅប្រើប្រាស់សំរាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលព្រៃឈើបានឡើយ ។

មូលនិធិនេះសំរាប់ប្រើប្រាស់ចំពោះតែសកម្មភាពនៃ :

១- ការដាំដើមឈើឡើងវិញ ។

២- កិច្ចការរុក្ខវប្បកម្មនិងការស្តារព្រៃឈើឡើងវិញ ។

៣- កិច្ចការពារនិងអភិរក្សព្រៃឈើ និងជីវៈចម្រុះ ។

៤- ការស្រាវជ្រាវបច្ចេកទេសនិងវិទ្យាសាស្ត្រនៃព្រៃឈើ និងសត្វព្រៃ ។

៥- ការផ្សព្វផ្សាយអំពីវិស័យព្រៃឈើ និងសត្វព្រៃ ។

៦- ការអភិវឌ្ឍន៍វិស័យព្រៃឈើ និងសត្វព្រៃ ។

៧- ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ។

៨- ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យព្រៃឈើ និងសត្វព្រៃ ។

ជំពូកទី ១៣
វិធានការគ្រប់គ្រងសកម្មភាពព្រៃឈើ

មាត្រា ៦៥.-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបង្កើតញញួររដ្ឋបាលព្រៃឈើកម្ពុជាដើម្បី :

១- វាយលើឈើស្របច្បាប់មុនពេលឱ្យដឹកជញ្ជូនចេញពីតំបន់ក្នុងព្រៃ ។

២- វាយលើឈើដែលជាវត្ថុតាងនៃបទល្មើសព្រៃឈើ ។

ស្លាកញញួររដ្ឋបាលព្រៃឈើកម្ពុជាមានរាងមូលហើយមានអក្សរកាត់ រ.ក. និងលេខនៅពីក្រោមតួអក្សរនោះ សម្រាប់សំគាល់ញញួរត្រានីមួយៗ ។

មុននឹងដាក់ឱ្យប្រើប្រាស់ញញួរត្រានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវធ្វើកំណត់ហេតុផ្តិតស្លាកញញួរត្រានេះ ហើយយកទៅតំកល់ទុកជាគំរូតាងនៅក្រសួងមហាផ្ទៃ និងតុលាការខេត្តក្រុង ។

មាត្រា ៦៦.-

ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាត្រូវតែបោះឱ្យបានផិតច្បាស់ដាច់ខាតដោយមន្ត្រីរដ្ឋបាលព្រៃឈើលើរាល់ឈើហ៊ុប ដូចតទៅ :

១- ឈើហ៊ុបស្របច្បាប់ដែលត្រូវដឹកជញ្ជូនចេញពីតំបន់ក្នុងព្រៃរហូតដល់ទីដៅកំណត់ ត្រូវមានស្លាកញញួររដ្ឋបាលព្រៃឈើកម្ពុជាចំនួនពីបួន (៤) ឡើងទៅនៅកន្លែងនីមួយៗ ខាងគល់និងខាងចុងឈើហ៊ុប ។

២- ឈើហ៊ុបល្មើសច្បាប់ដែលរដ្ឋបាលព្រៃឈើបានឃាត់ចាប់ត្រូវមានស្លាកញញួរត្រាបី(៣) គឺនៅខាងគល់ កណ្តាល និងខាងចុងឈើហ៊ុបដោយធ្វើឱ្យមានស្លាកបី(៣)រួមគ្នាបង្កើតជារាងត្រីកោណនៅកន្លែងនីមួយៗនោះ ។

ចំពោះដើមឈើដែលត្រូវអនុញ្ញាតឱ្យកាប់ក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានស្លាមញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជាចំនួនមួយ (១)ជាសំគាល់ ។

ការកាន់កាប់និងការប្រើប្រាស់ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា អាចប្រព្រឹត្តទៅបានតែចំពោះមន្ត្រីរដ្ឋបាលព្រៃឈើដែលបានធ្វើសច្ចាប្រណិធាន ។ វិធាននៃការគ្រប់គ្រងនិងប្រើប្រាស់ញញួរត្រានោះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ៦៧.-

រាល់ព្រៃសហគមន៍ ឬម្ចាស់ព្រៃគុបអាចមានញញួរត្រាឯកជនសម្រាប់វាយលើផលព្រៃឈើរបស់ខ្លួនផ្ទាល់ ប៉ុន្តែស្លាមញញួរត្រាឯកជននេះត្រូវមានរាង ទំហំ និងអក្សរសំគាល់ខុសពីស្លាមញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា ។

មុននឹងយកទៅប្រើប្រាស់ ព្រៃសហគមន៍ ឬម្ចាស់ព្រៃគុបត្រូវបញ្ជាក់សញ្ញាសំគាល់ និងត្រូវផ្តិតស្លាមញញួរត្រានោះ ទៅសុំការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ និងតម្កល់ទុកជាមុននៅការិយាល័យរដ្ឋបាលព្រៃឈើសាមី ។

មាត្រា ៦៨.-

ទោះជាមានលិខិតអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះក៏ដោយ ក៏ការកាប់ដើមឈើ ការប្រមូល ឬការដឹកជញ្ជូនផល អនុផលព្រៃឈើក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវហាមឃាត់ចាប់ពីម៉ោងប្រាំបី (៨) យប់ ដល់ម៉ោងប្រាំ (៥) ភ្លឺ ។

មាត្រា ៦៩.-

ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលចរាចរក្នុងទូទាំងប្រទេស ត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូនចេញដោយរដ្ឋបាលព្រៃឈើ ។

ផល អនុផលព្រៃឈើគ្រប់ប្រភេទក្រោយពេលបានកាប់រំលំ ត្រូវដឹកជញ្ជូនចេញពីព្រៃឱ្យអស់មកធ្វើសន្និធិនៅតំបន់អចិន្ត្រៃយ៍ ក្នុងអំឡុងពេលមិនឱ្យលើសពីមួយ(១)ខែឡើយ និងត្រូវអមដោយលិខិតអនុញ្ញាតដឹកជញ្ជូនចេញដោយរដ្ឋបាលព្រៃឈើ ។

ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលជាសន្និធិ ទោះជានៅទីណាក៏ដោយ ក៏ត្រូវអមដោយលិខិតអនុញ្ញាតដឹកជញ្ជូន ឬលិខិតអនុញ្ញាតសន្និធិចេញឱ្យដោយរដ្ឋបាលព្រៃឈើ ។

ការដឹកជញ្ជូនផល អនុផលព្រៃឈើ ឬសន្និធិខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាតដឹកជញ្ជូន ឬសន្និធិ ត្រូវចាត់ទុកជាល្មើសច្បាប់ ។

មាត្រា ៧០.-

មុនពេលបើកការដ្ឋានប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបត្រូវយកគ្រឿងចក្រ យានយន្ត និងសម្ភារយន្តគ្រប់ប្រភេទដែលបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើ ទៅសុំការអនុញ្ញាតចុះបញ្ជីនិងបិទស្លាកជាសំគាល់នៅរដ្ឋបាលព្រៃឈើ ។

គ្រឿងចក្រ យានយន្ត និងសម្ភារយន្តគ្រប់ប្រភេទដែលបំពីឱ្យការប្រមូលផល អនុ-ផលព្រៃឈើដោយពុំបានចុះបញ្ជី និងបិទស្លាកជាសំគាល់របស់រដ្ឋបាលព្រៃឈើ ហើយធ្វើចរាចរក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវហាមឃាត់។

រាល់គ្រឿងចក្រ យានយន្ត និងសម្ភារយន្តគ្រប់ប្រភេទដែលព្រៃសម្បទានិក ឬម្ចាស់ព្រៃគុបស្របច្បាប់មានបំណងធ្វើការនាំចូលដើម្បីបម្រើឱ្យការប្រមូលនិងដឹកជញ្ជូនផល អនុផលព្រៃឈើ ត្រូវឆ្លងកាត់ការវាយតម្លៃភាពសមស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

ការប្រើប្រាស់សម្ភារយន្តគ្រប់ប្រភេទដែលបំពីការប្រមូលផល អនុផលព្រៃឈើ ត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។

មាត្រា ៧១.-

Ministry of Social Action, Labor, Vocational Training and Youth Rehabilitation
Royal Cambodian Embassy in Paris
Royal Cambodian Embassy in Washington DC
US Embassy in Phnom Penh
EU Delegation in Bangkok
EU Delegation in Phnom Penh
Garment manufacturers Association in Cambodia
MOC Archives

Ministry of Commerce # 20 A & B Preah Norodom Boulevard Phnom Penh 12205 (Kingdom of Cambodia)
Minister' s Mobile Phone (855-12) 821888 Facsimile (855-23) 213288

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និង យុវនីតិសម្បទា

លេខ ៤៤៣ សកបយ

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០០២

ប្រកាស

ស្តីពី

ការជូនដំណឹងគ្រោះថ្នាក់ការងារ របៀបផ្តល់សំណងការងារ និង អត្រាធានារ៉ាប់រងសមត្ថភាពការងារ

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ /នស /៩៤ចុះថ្ងៃ ទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០៣៩៧/ ០១ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

សំរេច

ប្រការ ១.-

នាយក ឬ ម្ចាស់សហគ្រាស និងគ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម

កសិកម្ម សេវាកម្ម សហគ្រាសដឹកជញ្ជូនតាមផ្លូវគោកឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនាឬក្នុងសាសនា ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬ ជាការកុសល ព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគម ឬ ក្រុមហ៊ុនប្រភេទណាក៏ដោយត្រូវប្រកាសជូនដំណឹងជាលាយល័ក្ខអក្សរ អំពីគ្រោះថ្នាក់ការងារដែលបានធ្លាក់លើរូបកាយកម្មករ និយោជិតរបស់ខ្លួន។

ការប្រកាសជូនដំណឹងនេះ ត្រូវផ្ញើទៅនាយកដ្ឋានសន្តិសុខសង្គមនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះ បណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ប្រសិនបើ សហគ្រាសនោះមានទីតាំង នៅក្នុង ទីក្រុងភ្នំពេញ។ ចំពោះសហគ្រាស ដែលមានទីតាំងនៅក្នុងខេត្តក្រុងដទៃផ្សេងទៀតនិយោជក ឬម្ចាស់សហគ្រាសនោះ ត្រូវប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារ ទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះ បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទានៃខេត្ត ឬ ក្រុង ដែលសហគ្រាសនោះតាំងនៅ ។

ប្រការ ២.-

ការប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារត្រូវផ្ញើតាមសំបុត្រអនុសិដ្ឋ ឬ សំបុត្រជូនផ្ទាល់ដៃ ដោយមានបញ្ជាក់ថាបានទទួលហើយ ក្នុងរយៈពេលយ៉ាងយូរបំផុតសែសិបប្រាំបីម៉ោងបន្ទាប់ពីពេលមានគ្រោះថ្នាក់ ដោយមិនគិតថ្ងៃឈប់សំរាក ឬថ្ងៃបុណ្យ។

គំរូនៃសេចក្តីជូនដំណឹងអំពីគ្រោះថ្នាក់ការងារមានកំណត់ក្នុងឧបសម្ព័ន្ធទី ៦ នៃប្រកាសនេះ។

ប្រការ ៣.-

កម្មករនិយោជិតដែលទទួលរងគ្រោះថ្នាក់ការងារ ក៏ត្រូវមានកាតព្វកិច្ចជូនដំណឹងដល់និយោជក ឬអ្នកតំណាងពេញច្បាប់របស់និយោជកអំពីគ្រោះថ្នាក់ការងារដែលបានធ្លាក់មកលើខ្លួនក្នុងរយៈពេលយ៉ាងយូរបំផុតម្ភៃបួនម៉ោងបន្ទាប់ពីឧប្បត្តិហេតុកើតឡើង។ ទោះជាយ៉ាងនេះក្តី កាតព្វកិច្ចនេះអាចលើកលែងបានក្នុងករណីប្រធានសក្តិ ឬករណីដែលខ្លួនខ្វះលទ្ធភាពទាំងស្រុងដើម្បីធ្វើការជូនដំណឹងឬក៏ការមានមូលហេតុសមហេតុសមផលណាមួយផ្សេងទៀត។

ការជូនដំណឹង ដែលតំណាងកម្មករនិយោជិត ប្រធានក្រុម និងកម្មករនិយោជិត ផ្ញើជូនទៅនិយោជកឬអ្នកតំណាងនិយោជករបស់ខ្លួននោះ ត្រូវចម្លងជូននាយកដ្ឋានសន្តិសុខសង្គម ឬមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត ក្រុងផង។

ក្នុងករណីដែលមិនអាចជូនដំណឹងដោយផ្ទាល់នៅនឹងកន្លែងកើតហេតុ ដូចជាក្នុងករណីគ្រោះថ្នាក់នៅពេលធ្វើដំណើរ ដែលច្បាប់បានកំណត់ថាជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលបំពេញបេសកកម្មទាំងក្នុងឬក្រៅប្រទេសជាដើម សេចក្តីជូនដំណឹងនេះអាចធ្វើបានតាមរយៈសំបុត្រអនុសិដ្ឋ។

ប្រការ ៤.-

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលធ្វើការ

ទោះដោយ ហេតុយ៉ាងណាក៏ដោយ ហើយទោះបីមានកំហុសមកពីកម្មករនិយោជិតឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាថ្មី នៅទីកន្លែងណាក៏ដោយ ។

ម្យ៉ាងទៀតត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករនិយោជិតក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការឬពីកន្លែងធ្វើការ ទៅកន្លែងបើកប្រាក់ឈ្នួល ឬវិលមកវិញដោយគ្មានឈប់ ឬវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ ។

ជំងឺបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ដូចមានកំណត់ក្នុងច្បាប់ ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ។

ប្រការ ៥.-

នៅពេលមានគ្រោះថ្នាក់ការងារកើតឡើង និយោជកឬម្ចាស់សហគ្រាស នាយកដ្ឋានសន្តិសុខសង្គម មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទាខេត្ត ក្រុង ត្រូវមានភារកិច្ចចំពោះមុខដូចតទៅ ៖

ក. ចំពោះនិយោជក ឬម្ចាស់សហគ្រាស៖

- ចាត់ឱ្យមានការសង្គ្រោះជាបន្ទាន់ដល់ជនរងគ្រោះតាមគ្រប់មធ្យោបាយ
- ជូនដំណឹងទៅក្រសួងមានសមត្ថកិច្ច
- រក្សាសភាពដើមនៃទីកន្លែងកើតហេតុ " ចំពោះគ្រោះថ្នាក់ធ្ងន់ ឬគ្រោះថ្នាក់បណ្តាលឱ្យស្លាប់មនុស្ស "
- ក្នុងករណីតម្រូវឱ្យមានការផ្លាស់ប្តូរសភាពដើមនៃកន្លែងគ្រោះថ្នាក់ដោយសារការសង្គ្រោះត្រូវធ្វើកំណត់ហេតុ និង ថតទុកជាឯកសារ
- ផ្តល់ឯកសារដែលពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ដល់គណៈកម្មការអង្កេត
- បង្កលក្ខណៈងាយស្រួលដល់ជនដែលបានដឹងអំពីហេតុការណ៍គ្រោះថ្នាក់ ដើម្បីជនទាំងនោះអាចរាយការណ៍ជូនគណៈកម្មការអង្កេតបាន
- ធានារ៉ាប់រងគ្រប់ការចំណាយទាំងអស់នៃការអង្កេត ចំពោះតែការវិភាគបច្ចេកទេស
- អនុវត្តឱ្យបានត្រឹមត្រូវ នូវវិធានការដែលបានចុះនៅក្នុងកំណត់ហេតុ ។

ខ. ចំពោះនាយកដ្ឋានសន្តិសុខសង្គម៖

- ជូនដំណឹងជាបន្ទាន់ទៅនាយកដ្ឋានពេទ្យការងារ និងនាយកដ្ឋានអធិការកិច្ចការងារដើម្បីស្នើសុំមន្ត្រីមានសមត្ថភាព សំរាប់ចូលរួមក្នុងការអង្កេតគ្រោះថ្នាក់
- ចាត់តែងចុះពិនិត្យ អង្កេតដល់កន្លែងកើតហេតុផ្ទាល់ឱ្យបានឆាប់បំផុត ដែលអាចធ្វើបាន
- ស្នើសុំជំនួយពីអ្នកឯកទេសជំនាញ ក្នុងករណីគ្រោះថ្នាក់ដែលមានការពាក់ព័ន្ធនឹងសុខភាព

បច្ចេកទេសស្មុគស្មាញ។

គ. ចំពោះមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត ក្រុង÷

- ចាត់ចែងចុះពិនិត្យ និងធ្វើអង្កេតដល់កន្លែងកើតហេតុផ្ទាល់ឱ្យបានឆាប់បំផុត ដែលអាចធ្វើបាន
- ស្នើសុំជំនួយពីអ្នកឯកទេសជំនាញ ក្នុងករណីគ្រោះថ្នាក់ដែលមានការពាក់ព័ន្ធនឹងលក្ខខណ្ឌបច្ចេកទេសស្មុគស្មាញ
- ក្នុងករណីមានគ្រោះថ្នាក់ធ្ងន់ ឬដល់ស្លាប់ត្រូវជូនដំណឹងជាបន្ទាន់មកនាយកដ្ឋានសន្តិសុខសង្គមក្នុងរយៈពេលយ៉ាងយូរបំផុតចិតសិបពីរម៉ោង បន្ទាប់ពីបានទទួលដំណឹងពីសហគ្រាសដែលមានឧប្បត្តិហេតុ។

រាល់ពេលចុះអង្កេតគ្រោះថ្នាក់ការងារ ត្រូវធ្វើកំណត់ហេតុបញ្ជាក់ឱ្យបានច្បាស់លាស់អំពី ថាតើគ្រោះថ្នាក់នោះពិតជាគ្រោះថ្នាក់ការងារឬទេ មូលហេតុនៃគ្រោះថ្នាក់ និងត្រូវកំណត់វិធីសាស្ត្រសំរាប់បង្ការគ្រោះថ្នាក់ដដែលនេះកុំឱ្យកើតមានជាថ្មី ។ កំណត់ហេតុគ្រោះថ្នាក់ការងារ ត្រូវធ្វើតាមគំរូដូចមានចែងក្នុងឧបសម្ព័ន្ធ ២ នៃ ប្រកាសនេះ។

របាយការណ៍ប្រចាំ ឆមាស និងប្រចាំឆ្នាំអំពីគ្រោះថ្នាក់ការងារ ត្រូវធ្វើតាមតារាងគំរូដូចមានចែងនៅក្នុង ឧបសម្ព័ន្ធ ៣ និង ៤ នៃប្រកាសនេះ ។

ប្រការ ៦.-

ក្នុងពេលដែលបេឡាជាតិសន្តិសុខសង្គមមិនទាន់បង្កើត និយោជក ឬម្ចាស់សហគ្រាសដូចមានចែងក្នុងប្រការ ១ នៃប្រកាសនេះ ត្រូវមានកាតព្វកិច្ចផ្តល់តាវកាលិកសំរាប់ជួសជុលគ្រោះថ្នាក់ការងារបន្ថែមលើសោហ៊ុយ សំរាប់ជួយសង្គ្រោះគ្រាដំបូង ។ តាវកាលិកសំរាប់ជួសជុលគ្រោះថ្នាក់ការងារមានជាអាទិ៍ ដូចតទៅ÷

-ការជួយឧបត្ថម្ភសំរាប់ការព្យាបាល និងថែរក្សាជំងឺ

-ប្រាក់បំណាច់ប្រចាំថ្ងៃ

-ធនលាភ

-សោហ៊ុយសំរាប់បូជាសព និងធនលាភសំរាប់អ្នកនៅក្នុងបន្ទុករបស់អ្នករងគ្រោះ ។

ចំពោះគ្រោះថ្នាក់ចរាចរ ដែលមានលក្ខណៈជាគ្រោះថ្នាក់ការងារ ការជួសជុលដែលចេញឱ្យដោយភាគីទីបី ពោលគឺភាគីដែលបង្កឱ្យមានគ្រោះថ្នាក់ ក៏ត្រូវចាត់ទុកជាតាវកាលិកគ្រោះថ្នាក់ការងារដែរ។ និយោជកមានសិទ្ធិប្តឹងទាមទារឱ្យភាគីទីបីចេញតាវកាលិកគ្រោះថ្នាក់ប្រភេទនេះមកឱ្យខ្លួន ប្រសិនបើតាវកាលិកនេះសហគ្រាស បានសងទៅអ្នករងគ្រោះរួចហើយ។ ទោះជាមានចែងដូច្នេះក្តី តាវកាលិកផ្នែកនេះ ត្រូវតែស្ថិតនៅក្នុងបន្ទុកនិយោជកជាអ្នកទទួលរ៉ាប់រង ពោលគឺនិយោជកត្រូវរ៉ាប់រងរាល់

ការចំណាយទាំងអស់ជាមុនសិន រួចទើបដោះស្រាយជាមួយភាគីទីបី ជាក្រោយ។

អ្នករងគ្រោះដោយគ្រោះថ្នាក់ការងារ មានបុព្វសិទ្ធិពេញលេញក្នុងការទាមទារសោធនកាលិករបស់ខ្លួន ក្នុងករណីដែលតុលាការចេញសាលក្រមបញ្ជាក់ថាសហគ្រាសក្ស័យធន។

ប្រការ ៧.-

ការជួយឧបត្ថម្ភសំរាប់ការព្យាបាល និងថែរក្សាអ្នករងគ្រោះក្នុងរយៈពេលសំរាកព្យាបាលនៅមន្ទីរពេទ្យរាប់ទាំងការព្យាបាលពេលរបួស ឬជំងឺរើឡើងវិញ និងការជួយឧបត្ថម្ភផ្សេងៗបន្ទាប់ពីមុខរបួសបានជាសះស្បើយ គឺជាកាតព្វកិច្ចរបស់និយោជកចំពោះជនរងគ្រោះថ្នាក់ការងារ ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាកាលិក ឬបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ដោយផ្នែក ឬទាំងស្រុង បន្ទាប់ពីមានការបញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យ ផ្លូវការដែលមានការយល់ព្រមពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។ សោធនកាលិកផ្នែកនេះមានកំណត់ដូចតទៅ÷

- ប្រាក់ចំណាយសំរាប់ការព្យាបាល ការព្យាបាលដោយវះកាត់ ការព្យាបាលខាងទន្តសាស្ត្រ ការពិនិត្យដោយវិទ្យុកាំរស្មីអិចឬអេកូសាស្ត្រ ការពិនិត្យនៃមន្ទីរពិសោធន៍ និងរាល់ការវិភាគផ្សេងៗដែលគ្រូពេទ្យព្យាបាលតម្រូវឱ្យមាន
- ប្រាក់ចំណាយសំរាប់ទិញឱសថ និងគ្រឿងប្រើប្រាស់បន្ទាប់បន្សំទាក់ទងនឹងការព្យាបាល
- ប្រាក់ឧបត្ថម្ភសំរាប់អ្នកចាំថែរក្សាជំងឺនៅក្នុងមន្ទីរព្យាបាល ឬទីផ្សេងទៀតដែលមានលក្ខណៈជាកន្លែងសំរាប់ព្យាបាល
- ការផ្គត់ផ្គង់ ការជួសជុលឬកែកុនជាថ្មីនូវអវៈយវៈសិប្បនិម្មិត ឈើច្រត់ រទេះសំរាប់មនុស្សពិការ
- សោហ៊ុយសំរាប់ដឹកអ្នករងគ្រោះពីកន្លែងគ្រោះថ្នាក់ទៅមន្ទីរពេទ្យ ឬទៅកាន់លំនៅស្ថាន
- ការឧបត្ថម្ភសំរាប់ការងារសំរបសំរួលមុខងារឡើងវិញឬការជួយបង្រៀនវិជ្ជាជីវៈអោយបានសមស្របតាម កាយសម្បទារបស់ជនរងគ្រោះ ។

ទោះបីមានការកំណត់ដូចខាងលើក្តី ក៏អ្នករងគ្រោះ អាចនឹងមានសិទ្ធិទទួលនូវអត្ថប្រយោជន៍ប្រសើរជាងនេះថែមទៀត។

ប្រការ ៨.-

ក្នុងករណីគ្រោះថ្នាក់ការងារដែលបណ្តាលអោយបាត់បង់សមត្ថភាពការងារជាកាលិកឬជាអចិន្ត្រៃយ៍ដែលមានអត្រាតិចជាងម្ភៃភាគរយ ហើយមិនទាន់អាចចូលធ្វើការបាន ពោលគឺគ្រោះថ្នាក់ដែលបណ្តាលអោយ អាក់ខានធ្វើការមួយរយៈពេល ក្រៅពីអត្ថប្រយោជន៍ដូចមានចែងក្នុងប្រការ ៧ អ្នករងគ្រោះត្រូវមានសិទ្ធិទទួល នូវប្រាក់បំណាច់ប្រចាំថ្ងៃដែលនិយោជក ត្រូវបើកឱ្យចាប់ពីថ្ងៃទីប្រាំ

នៃថ្ងៃដែលមានគ្រោះថ្នាក់នេះទៅ រហូតដល់ជាសះស្បើយ ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យផ្លូវការ ដែលទទួលស្គាល់ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ប្រាក់បំណាច់ប្រចាំថ្ងៃ ត្រូវស្មើនឹងប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់អ្នករងគ្រោះ។

ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែករវាងប្រាក់ឈ្នួលមូលដ្ឋានរបស់អ្នករងគ្រោះនិងចំនួនថ្ងៃធ្វើការនៃអ្នករងគ្រោះ ។

ប្រាក់ឈ្នួលមូលដ្ឋាន គឺជាផលបូកនៃប្រាក់ឈ្នួលសុទ្ធសាធជាមួយអត្ថប្រយោជន៍ផ្សេងៗ ដូចជា ប្រាក់ម៉ោងបន្ថែម ប្រាក់ភារកិច្ច និងប្រាក់បំណាច់មួយចំនួនដែលមានលក្ខណៈ ជាសោហ៊ុយដូចជាសោហ៊ុយធ្វើដំណើរ សោហ៊ុយវិជ្ជាជីវៈ សោហ៊ុយបេសកកម្មជាដើម លើកលែងតែប្រាក់វិភាជន៍គ្រួសារ។

ចំនួនប្រាក់ឈ្នួលមូលដ្ឋានត្រូវកំណត់តាមលក្ខខណ្ឌដូចខាងក្រោម៖

១.បើការបើកប្រាក់ឈ្នួលប្រព្រឹត្តិទៅក្នុងមួយខែម្តង ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនប្រាក់ឈ្នួលសំរាប់ខែកន្លងទៅ គឺខែមុនខែដែលមានគ្រោះថ្នាក់ ។

២.បើការបើកប្រាក់ឈ្នួលប្រព្រឹត្តិទៅរៀងរាល់អឌ្ឍមាស ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនប្រាក់ឈ្នួលសំរាប់ពីរអឌ្ឍមាសបន្តបន្ទាប់មុនអឌ្ឍមាសដែលមានគ្រោះថ្នាក់ ។

៣.បើការបើកប្រាក់ឈ្នួលប្រព្រឹត្តិទៅរៀងរាល់សប្តាហ៍ ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនប្រាក់ឈ្នួល សំរាប់បួនសប្តាហ៍បន្តបន្ទាប់មកទល់នឹងសប្តាហ៍ដែលមានគ្រោះថ្នាក់ ។

៤.បើការបើកប្រាក់ឈ្នួលប្រព្រឹត្តិទៅជាប្រចាំថ្ងៃ ឬមិនទៀងទាត់ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនសរុបនៃប្រាក់ឈ្នួលប្រចាំថ្ងៃធ្វើការនិងថ្ងៃសំរាកដោយមានប្រាក់ឈ្នួលក្នុងរយៈពេលមួយខែគិតមកទល់នឹងថ្ងៃ ដែលអាក់ខានធ្វើការ ។

៥.បើការបើកប្រាក់ឈ្នួលប្រព្រឹត្តទៅក្នុងរយៈពេលលើសពីមួយខែ ប៉ុន្តែអាចបើកម្តងក្នុងមួយត្រីមាស ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនសរុបនៃប្រាក់ឈ្នួលសំរាប់រយៈពេលបីខែគិតមកទល់នឹងថ្ងៃអាក់ខានធ្វើការ។

៦.បើអ្នករងគ្រោះធ្វើការក្នុងមុខរបរប្រចាំរដូវ ឬប្រកបមុខរបរមិនជាប់លាប់ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនសរុបនៃប្រាក់ឈ្នួលសំរាប់រយៈពេលដប់ពីរខែគិតមកទល់ថ្ងៃ ដែលអាក់ខានធ្វើការ ។

ប្រាក់ឈ្នួលមូលដ្ឋានត្រូវគិតដូចគ្នាតាមលក្ខខណ្ឌខាងលើ បើសិនជាក្នុងរយៈពេលសាមសិបថ្ងៃគិតមកទល់ថ្ងៃគ្រោះថ្នាក់ អ្នករងគ្រោះមានផ្អាកការងារដោយមូលហេតុ ឈឺ គ្រោះថ្នាក់ធម្មតា ការសំរាលកូន ការឈប់សំរាកមានប្រាក់ឈ្នួល អវត្តមានដោយមានការអនុញ្ញាតត្រឹមត្រូវ ឬជំងឺ ឬមុខរបួសដែលបណ្តាលមកពីគ្រោះថ្នាក់ការងារលាប់ឡើងវិញ ។

ក្រោយពីមានការបញ្ជាក់ពីនាយកដ្ឋានពេទ្យការងារថា បានជាសះស្បើយអាចចូលបំរើការងារបានហើយ ÷

- បើសាមីជនមិនព្រមចូលបង្ហាញខ្លួនមកធ្វើការ ក្នុងរយៈពេល៦ថ្ងៃ (គិតតែថ្ងៃធ្វើការ) គិតពីថ្ងៃទទួលលិខិតបញ្ជាក់ខាងលើ ត្រូវចាត់ទុកថាបានបោះបង់ចោលការងារ។
- និយោជកត្រូវយកចិត្តទុកដាក់ទទួលសាមីជនឱ្យចូលធ្វើការវិញ ក្នុងករណីមិនអាចទទួលបានទេត្រូវផ្តល់ប្រាក់បំណាច់ជូនសាមីជនស្មើនឹងប្រាក់មធ្យមប្រចាំថ្ងៃចំនួន ១២ ខែ។

ប្រការ ៩._

ចំពោះករណីគ្រោះថ្នាក់ការងារ ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពីមួយភាគរយឡើងទៅ ឬ គ្រោះថ្នាក់ដល់ស្លាប់ និងដោយមានសេចក្តីបញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យផ្លូវការដែលទទួលស្គាល់ ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាផងនោះ អ្នករងគ្រោះ ឬ សិទ្ធិវន្តមានសិទ្ធិពេញលេញក្នុងការទទួលបាននូវតាវកាលិកជាធនលាភ ។

ធនលាភ គឺជាអនុគមន៍នៃប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ និងអត្រាបាត់បង់សមត្ថភាពការងាររបស់អ្នករងគ្រោះ។ ធនលាភសំរាប់គ្រោះថ្នាក់ការងារត្រូវផ្តល់ឱ្យបន្ទាប់ពីមុខរបួសបានជាសះស្បើយ។ នៅក្នុងរយៈពេលកំពុងព្យាបាលមុខរបួស ជនរងគ្រោះមានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃដូចមានចែងក្នុងប្រការ ៨ ខាងលើ។

ប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំរបស់អ្នករងគ្រោះត្រូវកំណត់តាមលក្ខខណ្ឌដូចខាងក្រោម÷

- ក្នុងលក្ខខណ្ឌធម្មតា ប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំស្មើនឹងចំនួនប្រាក់ឈ្នួលមូលដ្ឋានរបស់អ្នករងគ្រោះ ដូចមានកំណត់ក្នុងប្រការ ៨ ខាងលើ ក្នុងរយៈពេលដប់ពីរខែគិតមកទល់ថ្ងៃដែលអាក់ខានធ្វើការ ។
- ចំពោះអ្នករងគ្រោះដែលបំរើការក្នុងវិជ្ជាជីវៈណាមួយ ប៉ុន្តែមិនទាន់គ្រប់ដប់ពីរខែពេញលេញ បើគិតមកទល់ ថ្ងៃអាក់ខានធ្វើការដោយសារគ្រោះថ្នាក់ការងារ ប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងប្រាក់ឈ្នួលជាក់ស្តែង ក្នុងរយៈពេលដែលបានធ្វើការមកទល់ថ្ងៃអាក់ខានធ្វើការនោះ ។ ទោះបីមាន ខ បញ្ជាក់យ៉ាងនេះក៏ដោយ ក៏អ្នករងគ្រោះអាចមានសិទ្ធិទទួលអត្ថប្រយោជន៍ដូចក្នុងកថាខណ្ឌខាងលើ ឬប្រសើរជាង នេះ ។
- បើក្នុងថិរវេលាដប់ពីរខែគិតមកទល់ថ្ងៃមានគ្រោះថ្នាក់ការងារ អ្នករងគ្រោះបានអាក់ខានធ្វើការ ដោយសារ មានជំងឺ គ្រោះថ្នាក់ធម្មតា ការសំរាលកូន ការឈប់សំរាកដោយមានប្រាក់ឈ្នួល ឬអវត្តមានដោយមានច្បាប់ ប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ ត្រូវស្មើនឹងប្រាក់ឈ្នួលមធ្យមក្នុងរយៈពេលដប់ពីរខែគិតមកទល់ថ្ងៃដែលអាក់ខានធ្វើការដោយគ្រោះថ្នាក់ការងារ ។

ក្នុងករណីដែលមានការបាត់បង់សមត្ថភាពការងាររហូតដល់អត្រា ៥០%អ្នករងគ្រោះមានសិទ្ធិ

ទទួលបានធនលាភ ដែលត្រូវគណនាតាមរូបមន្តដូចខាងក្រោម÷

$R_1 = ½ SX_1$ *ដែលក្នុងនោះ*

R_1 - *ជាធនលាភប្រចាំឆ្នាំ*

S - *ជាប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ*

X_1 - *ជាអត្រាបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ពី ២០% ដល់ ៥០%។*

បើអត្រាបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍លើសពី ៥០% អ្នករងគ្រោះមានសិទ្ធិទទួលបានធនលាភ ដែលត្រូវគណនាតាមរូបមន្តដូចខាងក្រោម÷

$R_2 = S\,[½50\% + 1.5(X_2 - 50\%)]$ *ដែលក្នុងនោះ*

R_2 - *ជាធនលាភប្រចាំឆ្នាំ*

S - *ជាប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ*

X_2 - *ជាអត្រាបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដែលលើសពី ៥០%។*

នៅពេលដែលគ្រោះថ្នាក់ការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ទាំងស្រុងនិងតំរូវឱ្យមានមនុស្សនៅចាំថែរក្សា និយោជកត្រូវតម្លើងបន្ថែម ៤០% លើធនលាភដូចមានកំណត់ខាងលើ។

នៅពេលដែលទទួលបានធនលាភ អ្នករងគ្រោះមានសិទ្ធិទទួលបានការងារដែលមានលក្ខខណ្ឌសមស្របនឹងកាយសម្បទារបស់ខ្លួន។ ក្នុងករណីនេះ និយោជកត្រូវផ្ដល់ដល់ជនរងគ្រោះថ្នាក់ការងារនូវការបង្រៀនវិជ្ជាជីវៈឡើងវិញ ដើម្បីឱ្យជននេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារថ្មីរបស់ខ្លួន។

ក្នុងករណីដែល ភាគីទាំងពីរព្រមព្រៀងគ្នា និយោជកអាចផ្ដល់ប្រាក់ធនលាភផ្ដាច់តែម្ដង។

ប្រការ ១០.-

និយោជកត្រូវចាត់ចែងបញ្ជូនជនរងគ្រោះមកទទួលការពិនិត្យកាយសម្បទាសាឡើងវិញ នៅគាយកដ្ឋានពេទ្យការងារបន្ទាប់ពីមុខរបួសបានជាសះស្បើយ។ កាតព្វកិច្ចនេះ អនុវត្តតែចំពោះអ្នករងគ្រោះណាដែលអាក់ខានធ្វើការងារចាប់ពីប្រាំថ្ងៃឡើងទៅ។

សោហ៊ុយចំណាយ សំរាប់ការពិនិត្យកាយសម្បទាសាឡើងវិញ ត្រូវស្ថិតនៅក្នុងបន្ទុករបស់និយោជក។

ប្រការ ១១.-

និយោជកត្រូវទទួលបន្ទុកដោយពេញច្បាប់ក្នុងការផ្ដល់សោហ៊ុយសំរាប់បូជាសព និងធនលាភសំរាប់អ្នកនៅក្នុងបន្ទុកនៃអ្នករងគ្រោះថ្នាក់ការងារដល់ស្លាប់ ។ ត្រូវចាត់ទុកជាអ្នកនៅក្នុងបន្ទុកនៃអ្នករងគ្រោះ គឺជនដែលមាន លក្ខណៈសម្បត្តិដូចខាងក្រោម÷

-ភរិយា ឬប្តីពេញច្បាប់ដោយមានលិខិតបញ្ជាក់អត្រានុកូលដ្ឋាន និងមិនមានការលែងលះគ្នារហូតមកទល់ថ្ងៃមានគ្រោះថ្នាក់ ។

-កូនដែលនៅក្នុងបន្ទុករបស់ជនរងគ្រោះ ។ កូនដែលនៅក្នុងបន្ទុកជនរងគ្រោះគឺកូនដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងកូនដែលមានអាយុយ៉ាងច្រើន ១៦ឆ្នាំ ។ ប៉ុន្តែការកំរិតនេះអាចបន្ថែមដល់អាយុ ១៨ ឆ្នាំ ចំពោះកូនដែលកំពុងដាក់ឱ្យរៀនធ្វើការ និង ២២ ឆ្នាំ ចំពោះកូនដែលកំពុងបន្តការសិក្សានៅ ក្នុងគ្រឹះស្ថានសាធារណៈមធ្យមសិក្សា ឬឧត្តមសិក្សា ឬក្នុងគ្រឹះស្ថានឯកជនមធ្យមសិក្សា ឬឧត្តមសិក្សា ហើយមិនបានទទួលអាហារូបករណ៍ដោយមានការអនុញ្ញាតត្រឹមត្រូវ ព្រមទាំងកូនជាជនពិការឬមានជំងឺរ៉ាំរ៉ៃ មិនអាចព្យាបាលឱ្យជាសះស្បើយបាន ។

ប្រាក់ឧបត្ថម្ភ ដែលជាសោហ៊ុយសំរាប់ចាត់ចែងបូជាសពត្រូវកំណត់យ៉ាងតិចស្មើនឹង៩០ដងនៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ឬត្រូវស្មើនឹងប្រាក់ឈ្នួលសំរាប់បីខែរបស់អ្នករងគ្រោះ ។

ធនលាភសំរាប់ផ្តល់ឱ្យអ្នកនៅក្នុងបន្ទុកត្រូវកំណត់តាមអត្រាភាគរយនៃប្រាក់ឈ្នួលជាមូលដ្ឋានប្រចាំឆ្នាំនៃអ្នករងគ្រោះហើយអត្រានេះកំណត់ដូចតទៅ÷

-សាមសិបភាគរយ "៣០%" ចំពោះប្តី ឬប្រពន្ធអ្នករងគ្រោះ

-ដប់ប្រាំភាគរយ "១៥%" ចំពោះកូនទី១ និងទី២ ដែលកំព្រាឪពុក ឬម្តាយ

-ដប់ភាគរយ "១០%" ចំពោះកូនទី៣ តទៅដែលកំព្រាឪពុក ឬម្តាយ

ប៉ុន្តែចំនួនសរុបនៃធនលាភសំរាប់អ្នកនៅក្នុងបន្ទុកមិនអាចលើស ៨៥% នៃចំនួនប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំនោះឡើយ ។

សិទ្ធិនៃការទទួលធនលាភនៃប្តី ឬប្រពន្ធដូចមានកំណត់តាមលក្ខខណ្ឌខាងលើត្រូវផុតរលត់ក្នុងករណីជនទាំងនោះរៀបអាពាហ៍ពិពាហ៍ម្តងទៀត ។

ប្រាក់ធនលាភនេះ អាចបើកប្រចាំខែ ឬអាចបើកផ្តាច់តាមការព្រមព្រៀងគ្នារវាង និយោជក និងសិទ្ធិវន្តនៃអ្នករងគ្រោះ។

ប្រការ ១២.-

ដោយអនុលោមតាមប្រភេទនៃមុខរបួស និងលក្ខណៈទូទៅផ្សេងទៀតដូចជា អាយុ កំលាំងកាយ ស្មារតី សម្បទា, និងលក្ខណៈសម្បត្តិនៃវិជ្ជាជីវៈ អត្រានៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវកំណត់ក្នុង ឧបសម្ព័ន្ធទី ៥នៃប្រកាសនេះ ។

ប្រការ ១៣.-

នាយកដ្ឋានពេទ្យការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវធ្វើការសិក្សាស្រាវជ្រាវ និងលើកសំណើប្រភេទជំងឺវិជ្ជាជីវៈ។ -/-/ -

ប្រការ ១៤.-

ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវទទួលពិន័យឬទទួលទោសដូចមាន ចែងក្នុងជំពូក ទី ១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ ១៥.-

ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៥៨ សកអ ចុះថ្ងៃទី ១២ ខែកុម្ភៈឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១៦.-

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

កន្លែងផ្ញើ :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប "
-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទាខេត្ត ក្រុង " ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
-សមាគមនិយោជក " ដើម្បីជ្រាប "
-សហព័ន្ធសហជីព " ដើម្បីជ្រាប "
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ " ដើម្បីជួយផ្សព្វផ្សាយ "
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធទី១នៃប្រកាស

លេខ សកបយ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ការប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារ

លោក/លោកស្រី...

ម្ចាស់ ឬនាយកសហគ្រាស ឬក្រុមហ៊ុន ....

អាសយដ្ឋាន..

....

គោរពជូន

លោកប្រធាន

☐ នាយកដ្ឋានសន្តិសុខសង្គម [១]

☐ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត ឬក្រុង...

<u>កម្មវត្ថុ</u> : ប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារ

១_កាលបរិច្ឆេទនៃគ្រោះថ្នាក់ការងារ :

ម៉ោង.............ថ្ងៃទី............ខែ..............ឆ្នាំ.......ទីកន្លែង.................

២_ប្រភេទគ្រោះថ្នាក់ការងារ...

....

....

៣_ចំនួនអ្នករងគ្រោះ :

- ស្លាប់:...
- របួសធ្ងន់:..
- របួសស្រាល:..

៤_មូលហេតុនៃគ្រោះថ្នាក់ "បរិយាយលំអិត ".......................................

....

....

[១] គូសក្នុងចន្លោះណាដែលត្រូវធ្វើ

ធ្វើនៅ...............ថ្ងៃទី......................

ហត្ថលេខានិយោជក ឬម្ចាស់សហគ្រាស

ឧបសម្ព័ន្ធទី ២ នៃប្រកាស

លេខ សកបយ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា

កំណត់ហេតុ

អង្កេតគ្រោះថ្នាក់ការងារ

ឆ្នាំ .... ខែ .... ថ្ងៃទី .... ម៉ោង .... គណៈកម្មការអង្កេតគ្រោះថ្នាក់ការងាររបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានចុះធ្វើអង្កេតករណីគ្រោះថ្នាក់ ដែលបានកើតឡើងនៅ ៖

សហគ្រាស/ក្រុមហ៊ុន:..

អាស័យដ្ឋាន:..

១- ករណីគ្រោះថ្នាក់

☐ ស្លាប់

☐ របួសធ្ងន់

☐ របួសស្រាល

២- ប្រភេទគ្រោះថ្នាក់ ៖ (ភ្លើងឆក់, ម៉ាស៊ីនកាប, ធ្លាក់ពីទីខ្ពស់, សំភារៈ ឬឧបករណ៍ធ្លាក់ ឬសង្កត់លើ, ផ្ទុះឧបករណ៍សម្ពាធខ្ពស់ ។ល។)

☐ ....

☐ ....

☐ ....

☐ ....

៣- សមាសភាពគណៈកម្មការអង្កេត

☐ ....

☐ ....

☐ ....

☐ ....

☐ ....

☐ ....

៤- ជីវប្រវត្តិជនរងគ្រោះ

☐ ឈ្មោះ..ភេទ..អាយុ..

- មុខជំនាញ..
- អតីតភាពមុខជំនាញ..
- អតីតភាពការងារ..
- រូបភាពផ្តល់បៀវត្ស..
- សញ្ជាតិ..
- ធ្លាប់ទទួលការបណ្តុះបណ្តាលបច្ចេកទេសសន្តិសុខការងារឬទេ
  - ☐ ធ្លាប់
  - ☐ មិនធ្លាប់

☐ ស្ថានភាពគ្រួសារ (អ្នកនៅក្នុងបន្ទុក, កិរិតជីវភាព) ....

☐ ឈ្មោះ..ភេទ..អាយុ..

- មុខជំនាញ..
- អតីតភាពមុខជំនាញ..
- អតីតភាពការងារ..
- រូបភាពផ្តល់បៀវត្ស..
- សញ្ជាតិ..
- ធ្លាប់ទទួលការបណ្តុះបណ្តាលបច្ចេកទេសសន្តិសុខការងារឬទេ
  - ☐ ធ្លាប់
  - ☐ មិនធ្លាប់
- ស្ថានភាពគ្រួសារ (អ្នកនៅក្នុងបន្ទុក, កិរិតជីវភាព) ....

៥-ទិដ្ឋភាពនៃ[illegible] ([illegible]របស់គ្រូពេទ្យប្រចាំសមាគ្រាស និង/ឬ មន្ត្រីអង្កេត)

- ☐ ថ្ងៃ.............................ខែ...........................ឆ្នាំ.......................វេលាម៉ោង..
- ☐ មុន ឬ [illegible] ក្រោយ[illegible]
- ☐ ពេល[illegible]
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....

៦-សាក្សី

- ☐ ....
- ☐ ....
- ☐ ....
- ☐ ....

៧-មតិនិយោជក.

- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....

៨-មតិប្រតិភូបុគ្គលិក ឬ សហជីព

- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....

៩-មូលហេតុនៃគ្រោះថ្នាក់

- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....

១០-វិធានការទប់ស្កាត់

- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....

១១-សេចក្តីសន្និដ្ឋានរបស់គណកម្មការអង្កេត

- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....
- ☐ ....

នាយកសហគ្រាស ឬតំណាង | សាក្សី | ប្រធានគណៈកម្មការអង្កេត

ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អង្គភាព/ក្រុមហ៊ុន :..........................

អាសយដ្ឋាន :..................................

នៃប្រកាសលេខ:................

បញ្ជីគ្រោះថ្នាក់ការងារ

ល.រ/No.		ឈ្មោះ NAME	មុខរបរ JOB	ភេទ SEX	អាយុ AGE			អតីតភាពការងារ employment age	អតីតភាពជំនាញ SKILLED SENIORITY			កំរិតគ្រោះថ្នាក់ ACCIDENT SEVERITY			ចំនួនថ្ងៃឈប់ធ្វើការ WORKING DAY LOSS	[illegible] BENEFITS (X 1000 Riels)	ប្រភេទគ្រោះថ្នាក់ TYPE OF THE ACCIDENT	មូលហេតុ CAUSES				វគ្គបណ្តុះបណ្តាលសុវត្ថិភាព SAFETY TRAINING (yes/no)
គ្រោះថ្នាក់ការងារ LABOUR ACCIDENT	ជនរងគ្រោះ VICTIM				តិចជាង ៣០ < 30 YEARS OLD	ពី៣០ ទៅ ៤០ FROM 30-40 YEARS OLD	៤០ឆ្នាំឡើង > 40 YEARS OLD		តិចជាង ៥ឆ្នាំ <5 years	ពី៥ដល់ ១០ឆ្នាំ FROM 5 - 10 YEARS	១០ឆ្នាំឡើង >10 YEARS	ស្លាប់ DEATH	ពិការតិចជាង២០% < 20% OF PERT. INCAPACITY	ពិការលើស ២០% > 20% OF PERT. INCAPACITY				ឧបករណ៍ផលិតកម្ម PRODUCTIVE AGENCIES	អនាម័យការងារ LABOUR HYGIENE	សម្ភារៈការពារខ្លួន PER. PROT. EQUIPMENT	រំលោភបទបញ្ជា RULE VIOLATION	
១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២	២៣

១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២	២៣
សរុប																						

ធ្វើនៅ............ថ្ងៃទី ខែ ឆ្នាំ

ប្រធានអង្គភាព

សហគ្រាស/ក្រុមហ៊ុន :..........................

អាសយដ្ឋាន :....................................

ឧបសម្ព័ន្ធទី៤

នៃប្រកាសលេខ:................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍សរុបគ្រោះថ្នាក់ការងារ

ប្រភេទគ្រោះថ្នាក់ Type of Accident	ចំនួនគ្រោះថ្នាក់ការងារ (ដង) Number of accident (time)			ចំនួនមនុស្សគ្រោះថ្នាក់ការងារ (នាក់) Number people accident (person)													ចំនួនថ្ងៃឈប់ធ្វើការ Working day loss	[illegible] Benefits (x 1000 Riels)	មូលហេតុ Causes					វគ្គបណ្តុះបណ្តាលសុវត្ថិភាព Saf. Training (yes/ no)
						ស្លាប់ Death		>20%		<20%	អាយុ Age			អតីតភាពមុខជំនាញ Skilled Seniority								ការរំលោភបទបញ្ជា RULE VIOLATION		
	សរុប Total	ស្លាប់ Death	ច្រើននាក់Many People	សរុប Total	ស្រី Female	សរុប Total	ស្រី Female	សរុប Total	ស្រី Female		តិចជាង ៣០ < 30 years old	ពី៣០ ទៅ ៤០ From 30 to 40 years old	៤០ឡើង > 40 years old	តិចជាង ៥ឆ្នាំ < 5 years	ពី៥ដល់ ១០ឆ្នាំ From 5 - 10 years	១០ឆ្នាំឡើង >10 years			សម្ភារផលិតកម្ម Productive Agencies	អនាម័យការងារ Labor hygiene	សម្ភារៈការពារខ្លួន Per. Prot. Equipment	អ្នកគ្រប់គ្រង Manager	កម្មករនិយោជិត Workers	
១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២	២៣	២៤	២៥

១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២	២៣	២៤	២៥
សរុប																								

ធ្វើនៅ............ថ្ងៃទី ខែ ឆ្នាំ

ប្រធានអង្គភាព

ឧបសម្ព័ន្ធទី ៥ នៃប្រកាស
លេខ: សកបយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លក្ខណៈវិនិច្ឆ័យសំរាប់ការចាត់ថ្នាក់នៃ
ការបាត់បង់សមត្ថភាពការងារ

ការបាត់បង់សមត្ថភាពចំពោះការងារត្រូវចាត់ថ្នាក់ជា ៤ ប្រភេទ :

ប្រភេទទី ១ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់សាមីជនដែលមានការខ្ទេចខ្ទាំយ៉ាងធ្ងន់ធ្ងរនៃមុខងារសំខាន់ៗ និងជាសរីរាង្គមួយ ឬច្រើន របស់សរីរាង្គកាយ ។ ជនពិការពុំអាចធ្វើការងារចិញ្ចឹមខ្លួនឯងបាន និងតម្រូវឱ្យមានអ្នកដទៃជួយជាអចិន្ត្រៃយ៍ ។

ប្រភេទទី ២ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់ក្នុងករណីដែលមានការខ្ទេចខ្ទាំធ្ងន់ ឬស្រាល នៃមុខងារសំខាន់ៗរបស់សរីរាង្គកាយ ។ ជនពិការ អាចប្រកបការងារបាននៅក្នុងករណីពិសេស ។ សាមីជនោះអាចធានាបានដោយខ្លួនឯងនូវសេចក្តីត្រូវការរបស់ខ្លួនមួយផ្នែកក្នុង ជីវភាពប្រចាំថ្ងៃដោយមិនបាច់ពឹងផ្អែកជំនួយជាអចិន្ត្រៃយ៍ពីអ្នកដទៃឡើយ ។

ប្រភេទទី ៣ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់ក្នុងករណីដែលមានការចុះថយនៃសមត្ថភាពធ្វើការងារ ។ ជនពិការអាចចំពីការងារបាននៅក្នុង ករណីដែលបានកំណត់ ហើយមិនទាមទារឱ្យមានអ្នកដទៃជួយក្នុងជីវភាពប្រចាំថ្ងៃឡើយ ។

ប្រភេទទី ៤ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់ក្នុងករណីដែលសមត្ថភាពការងារត្រូវថយចុះ និងសភាពសុខភាពតម្រូវឱ្យផ្លាស់ប្តូរវិជ្ជាជីវៈ ឬតម្រូវឱ្យ ផ្លាស់ប្តូរលក្ខណៈការងារ ។

ឧបសម្ព័ន្ធ ១

សំណល់នៃអាហ្វិចស្យុង "ជំងឺព្រួយ" ការប៉ះទង្គិច" បណ្តាលពីគ្រោះថ្នាក់នៃការងារ	:	អត្រាបាត់បង់សមត្ថភាពការងារ(%)
ក-ក្បាល មុខ ក :		
១-ការប៉ះទង្គិចលលាដ៍:		
-ខ្ទិនមួយចំហៀងខ្លួនមិនពេញលេញ វិបត្តិនៃពាក្យសំដី	:	៧០-៨០
-ខ្ទិនមួយចំហៀងខ្លួនមិនពេញលេញ វិបត្តិសាច់ដុំ	:	៧០-៨០
-ឆ្កួតជ្រូកញឹកញាប់ កើតមានច្រើនដងក្នុងមួយសប្តាហ៍	:	៧៥-១០០
-វិលមុខ ភ្លេចភ្លាំង "ឆ្កួតជ្រូកស្រាល" កើតឡើងដោយធ្ងន់ធ្ងរ	:	៤០-៨០
-មានសិក "ប្រាជ្ញាស្មារតី," ខូចខាត" ភាពវិកលចរិត ភាពលីលា" ធ្ងន់ធ្ងរ	:	៦១-១០០
២-អន្ធការភ្នែកទាំងពីរ.ការឃើញ សរុប ១/២០	:	៨០
៣-អន្ធការទាំងស្រុងនៃភ្នែកទាំងពីរ "ខ្វាក់"	:	៥០
៤-បាត់បង់ឆ្អឹងថ្គាមខាងក្រោម	:	៦០-៧០
៥-ជំរៀបចំពង់សំលេង ដើមក ហត់ដង្ហើមមិនធ្ងរស្រាល	:	៥០-៦០

ខ.ឆ្អឹង និងសន្លាក់ឆ្អឹងខ្នង

១-វះកាត់ស្ពូត សមត្ថភាពឯកជនថ្លើមថយចុះជាង៥០ភាគរយ
សុខភាពទូទៅ ត្រូវរងគ្រោះ "ថយចុះ" : ៥៥-៧៥

២-ប៉ះពាល់ដល់ស្រោមបេះដូង ឬហូរឈាមពោល បើកការវះ "សាច់បេះដូង" "ម្ការវះ"
ប្រើសរសៃដូងបង្គ្រប់ឱ្យមានវិបត្តិសម្ពាធបេះដូង : ៥៥-៧០

គ.ឆ្អឹងខ្នង : ដំណើរឆ្អឹងខ្នងជាមួយនឹងការរៀបរៀងឆ្អឹងខ្នង :

១-ខ្វិនសងខាងមិនពេញលេញនៃអវយវៈក្រោម ធ្វើបាតលំបិនខ្វះដំណើរ
និងវិបត្តិសាច់ដុំរលើង និងសរ : ៤០-៧០

២-ខ្វិនសងខាងទាំងស្រុងនៃអវយវៈក្រោម : ៧០-៨០

៣-ខ្វិនទាំងបួន "ដៃពីរ ជើងពីរ" មិនពេញលេញ : ៨០-៩០

៤-ខ្វិនបួនទាំងស្រុង "អាចទាំងជើង ទាំងដៃ" : ១០០

៥-អាការៈរោគនៃកន្ទុយសេះ "កីឡូវ៉ាំង" ខ្វិនសងខាង វិកលភាព សាច់ដុំរលើង និងសរ
បាត់បង់អារម្មណ៍មិនអាចសិល : ១០០

ឃ.អាងៈ និងសរីរាង្គអាងៈ :

-ជាប់រោគសៀតធំ ទ្វារលាមកមិនប្រក្រតី : ៤០-៧០

ង.អវយវៈ :

១-កាត់ដៃទាំងពីរ "មិនថាហោះកាត់ត្រឹមណា" : ៧៥-៨៥

២-កាត់ប្រអប់ជើងទាំងពីរ : ៧០-៨០

៣-កាត់ជើងទាំងពីរ "មិនថាហោះកាត់ត្រឹមណា" : ៧០-៨០

៤-កាត់ជើងដៃម្ខាង និងប្រអប់ជើងម្ខាង

-មានជើងដាក់ជំនួសមាន "ជើងសិប្បនិម្មិត" : ៧៥-៨០

-គ្មានជើងដាក់ជំនួសមាន : ៨០-៩០

៥-បាត់បង់អវយវៈបី "ដៃពីរជើងមួយ ឬ ផ្ទុយ" : ១០០

៦-ខ្វិនទាំងស្រុងនៃអវយវៈពីរ ឬច្រើនជាងនេះ "ឬមួយអវយវៈលើ ២ ឬមួយអវយវៈ
ក្រោម២ ឬមួយអវយវៈលើមួយក្រោមមួយ : ៧០-៨៥

ប្រភេទទី ២

ក.ក្បាល ខួរ ក :

១-ខ្វិនមួយចំហៀងខ្លួនមិនពេញលេញ ធ្វើបាតលំបិនទៅដំណើរ : ៤០-៧០

២-ថ្កូវ និងភាពគ : ៤០-៦០

៣-ឆ្កួតជ្រូកច្រើនដង : ៣០-៤៥

៤-វិលមុខឆ្កួតជ្រូកញឹកញាប់ "ពីដងក្នុងមួយសប្តាហ៍" : ៣០-៤០

៥-ឆ្កួតជ្រូកដោយអង្គៀ កើតវិបត្តិជាប់១ថ្ងៃ : ៣០-៥០

៦-អាហ្វាស៊ី - និយាយមិនរួច : ២០-៥០

៧-វិបត្តិលើរូប បន្ទាប់ពីការប៉ះទង្គិច ឬអាការៈរោគបន្ទាប់ពីការប៉ះទង្គិច : ៣០-៤០

៨-ភាពថ្លឹកថ្លៃ "អាំណេស៊ី" បន្ទាប់ពីការប៉ះទង្គិច : ៣០-៤០

៩-ហ៊ីតែរ អេម៉ូស្យុង "ឆាប់រំភើបចិត្តខ្លាំងពេក" : ៣០-៤០

១០-ផ្ដាកនោមស្វ័យប្រវត្តិ "អាការៈរោគពិស្វីភ្ល័យ" : ២០-៤០

១១-មានសតិ (សតិបញ្ញា) ទន់ខ្សោយ : ៤៥-៦០

១២-មានសិកស្រុតចុះ : ៤០

១៣-ថ្លង់សងខាងទាំងស្រុង : ៤៥

១៤-ជំងឺរលាកបំពង់សំឡេង-វះចោះបំពង់ខ្យល់ : ៥០-៦០

១៥-បំពង់អាហាររួមតូច ត្រូវឱ្យអាហារតាមវះក្រពះ : ៤០-៦០

១៦-គំហើញនៃភ្នែកទាំងពីរថយចុះ

-ការគំហើញ (អាគ្វីតេ) ២/១០ : ៦០

-ការគំហើញ (អាគ្វីតេ) ១/១០ : ៧០

១៧-បាត់បង់ពន្លឺភ្នែកខាងណើ : ៥០-៦០

១៨-ភ្នាក់ផ្លឹងភ្នែកមានសមត្ថភាពមើលតែសារជាតិភ្លឺ : ៤០-៦០

១៩-ខ្វិនសាច់ដុំអណ្ដាតទាំងស្រុង "អាប់អណ្ដាត" : ៥០

២០-អណ្ដាតដាច់ដោយសារប៉ះទង្គិច : ៥០

ខ-ទ្រូង និងសរីរាង្គទ្រូង :

១-វះកាត់សួត "តូម៉ុងអ៊ីទ្ធូមី" សមត្ថភាពដកដង្ហើមថយចុះតិចជាង៥០% : ៣៥-៤៥

២-កើតជំងឺនៅស្រោមបេះដូង "បញ្ជូវ៉ានអាស លើការង មីត្រាល សាច់បេះដូង" ច្រើស "រ៉ាំរ៉ៃ" មិនបណ្ដាលឱ្យមានវិបត្តិដល់មុខងារសំខាន់ៗរបស់បេះដូង : ៣០-៥០

គ-ឆ្អឹងខ្នង :

១-ខ្វិនឈេងខាងមិនពេញលេញ មានសមត្ថភាពអាចរំកិលខ្លួនបាន : ២៥-៤០

២-ខ្វិនជាសន្លឹងខ្នងសងខាង : ២៤-៤០

៣-បាក់ឆ្អឹងតូច ធ្លាប់រឺបត្តិនៃសាច់ដុំជើង និងដៃ : ២៥-៣៥

ឃ-ពោះ និងសរីរាង្គពោះ :

១-ការប៉ះទង្គិចផ្ទៃពោះ ប៉ះពាល់ដល់ក្រពះជាមួយនឹងផលវិបាក : ជំងឺរលួយ ខ្វះឈាម ស្លេកស្លាំង (anémie) ស្គមស្គាំង : ៣៥-៤៥

២-វះកាត់ក្រពះ : ៤០ -៦០

៣-វះកាត់ពោះវៀនតូចលើសពីមួយម៉ែត្រ ជាមួយនឹងវិបត្តិនៃការរំលាយអាហារ : ៣៥-៦០

៤-ជំងឺពោះវៀនតូច និងថ្លាយរន្ធធំនៅភាគខាងឆ្វេង : ២៥-៤០

៥-រន្ធថ្លាយធំនៃពោះវៀនធំជាមួយនឹងការហូរលាមក : ៣០-៤០

៦-ចោះផ្លាកនោមនៅផ្ទៃពោះ "រន្ធនោមសិប្បនិម្មិត : ៣០-៤០

៧-កាត់តម្រងនោមម្ខាងចោល : អ៊ុយរេឈាម ០,៦ - ១ក្រាមក្នុងមួយលីត្រ : ៣៥-៤៥

អ៊ុយរេឈាមច្រើនជាងមួយក្រាមក្នុងមួយលីត្រ : ៤៥-៦៥

ង-ប្រដាប់ភេទ សរីរាង្គនៃប្រដាប់ភេទ ឬជាអវយវៈបន្តពូជ "អង្គជាតិ" :

១-បាក់ឆ្អឹងត្រគាកជាមួយនឹងការខូចទ្រង់ទ្រាយត្រគាករបស់ស្ត្រីក្នុងអាយុកាលអាចឱ្យកំណើតកូនបាន : ៣០-៤០

២-វះកាត់ស្បូននៃស្ត្រីមិនដែលមានកូន : ៣៥-៤៥

៣-កាត់សុដនចោលទ្វេនារីវ័យក្មេង	៖	៣៥-៤៥
៤-កាត់លិង្គបុរសនៅមិនទាន់មានកូន	៖	៣៥-៤៥
៥-បាត់បង់ពងស្វាសទាំងពីរនៃបុរសមិនដែលមានកូន	៖	២៥-៤០

ខ-អវយវៈ :

១-បាត់បង់ប្រអប់ដៃម្ខាង	៖	៣៥-៤០
២-កាត់ត្រង់សន្លាក់ឆ្អឹងកដៃ	៖	៣៥-៤០
៣-កាត់កំភួនដៃ	៖	៤០-៤៥
៤-កាត់ត្រង់សន្លាក់ឆ្អឹងកែងដៃ	៖	៤០-៤៥
៥-កាត់ឆ្អឹងដើមដៃ :		
-ពាក់កណ្ដាលខាងក្រោម	៖	៤៥-៥០
-ពាក់កណ្ដាលខាងលើ	៖	៥០-៥៥
៦-កាត់ត្រង់សន្លាក់ឆ្អឹងស្មា	៖	៥៥-៦០
៧-ខ្វិនទាំងស្រុង "ងាប់" នៃដៃម្ខាង	៖	៤៥-៥០
៨-អាការៈរោគនៃការឈឺចាប់កូសាល់ "កូសាល់ឈឺ" ខូចខាតទាំងស្រុងនៃដើមដៃម្ខាង	៖	៤៥-៥០
៩-កាត់ស្មងម្ខាង	៖	៣៥-៥០
១០-កាត់ត្រង់សន្លាក់ជង្គង់	៖	៣៥-៤០
១១-កាត់ភ្លៅ	៖	៣៥-៤០
១២-ខ្វិនទាំងស្រុង "ងាប់" នៃជើងម្ខាង	៖	៤៥
១៣-ភ្ជាត់ឆ្អឹងចង្កេះជាមួយនឹងរបួសសាច់ភ្លៅ	៖	៤៥
១៤-កាត់សន្លាក់ឆ្អឹងចង្កេះ "គ្មានសន្លាក់ឆ្អឹងចង្កេះ"	៖	៥០-៧០

ប្រភេទទី ៣

ក-ក្បាល មុខ ក :

១-រលាត់ស្បែកលលាដ៍	៖	១៥-៣០
២-កាត់ឆ្អឹងលលាដ៍ចោលមួយចំណែក :		
-វិជ្ជមាត្រលើសពីរ ៦ ស.ម	៖	២០-៣០
-វិជ្ជមាត្រលើសពី ១០ ស.ម	៖	៣០-៤០
៣-អង្គធាតុជំនែនៅក្នុងប្រអប់លលាដ៍	៖	២០-៣០
៤-ហេមីប៉ារេស៊ី	៖	២០-៤០
៥-និយាយមិនច្បាស់ស្ទើតែទាំងស្រុង	៖	២០-៣០
៦-ឆ្កួតជ្រូកទូទៅ :		
-រម្ងឹល "ម្ដងទៅពីរដងក្នុងមួយខែ"	៖	១៥-៣៥
-កម្រ " ៣ដងទៅ ៤ដងក្នុងមួយឆ្នាំ "	៖	១០-១៥
៧-វិលមុខ ភ្លេចភ្លាំង "ឆ្កួតជ្រូកស្រាល" "សណ្ឋានស្រាល"	៖	២០-៣០
៨-ឆ្កួតជ្រូកតិចតួច "មិនជាឆ្កួតជ្រូក" ឃាកសួន " ម្ដងក្នុងមួយសប្ដាហ៍	៖	២០-៣០

៩-ចលនាមិនធម្មតា "ញ័រទទ្រើកប្រកាច់... លំបាកលំបិនក្នុងការងារនៃភាពផតល្បឿង

"ជាក់លាក់" ៖ ១០-៤០

១០-អាការៈរោគផ្ដាច់ខ្លួន "ស៊ីបហ្វ្រិកទីហ្វ" ជាប់បន្តពីការរបួសខួរក្បាលស្បូងខួរ ៖ ២០-៣០

១១-អាស្ដីនីបន្ទាប់ពីការប៉ះទង្គិច "សណ្ឋានមធ្យម ,កណ្ដាល" ៖ ២០-៣០

១២-ហ៊ីពែរអេម៉ូទីវីត "ភាពឆាប់រំភើបចិត្តខ្លាំងពេក" ហារម្ភ, មនៃគិត "សណ្ឋានមធ្យម" ៖ ២០-៣០

១៣-សភាពស្រុតចុះនៃណឺរ៉ូ "មធ្យម ល្មម" ៖ ១០-៣០

១៤-សណ្ឋានឆ្កួតជ្រូកទាពេលព្រលប់ "សន្និប្រកាស" ៖ ២៥-៣០

១៥-ថ្លង់ទាំងសងខាងមិនពេញលេញ ៖ ៣០-៤០

១៦-បំពង់ច្រមុះរួមតូច "កុងម៉ីណាសាល់" ដកដង្ហើមតាមមាត់ ៖ ២០-៣០

១៧-អន្ធការភ្នែកម្ខាង ខូចទ្រង់ទ្រាយគ្រាប់ភ្នែកម្ខាងទៀត ៖ ២៥-៣០

១៨-កាត់គ្រាប់ភ្នែកម្ខាងចោល

-មានលទ្ធភាពដាក់កែវភ្នែកជំនួសបាន "កែវភ្នែកសិប្បនិម្មិត" ៖ ២៥-៣០

-គ្មានលទ្ធភាពដាក់កែវភ្នែកជំនួសបាន ៖ ៣០-៣៥

១៩-បាក់ឆ្អឹងថ្គាមខាងលើជាមួយនឹងផ្នែកឆ្អឹងមានគុណវិបត្តិ និងភ្ជាប់
រៀងផ្ដា ថ្គាម អសមត្ថភាពនៃការរំលាយអាហារ ៖ ៣០-៤០

២០-បាក់ឆ្អឹងថ្គាមក្រោម ផ្នែកឆ្អឹងមានគុណវិបត្តិ ការញែក ខុស កន្លែងនៃសន្លាក់ធ្មេញ
"កន្លែងដែលធ្មេញលើនិងក្រោមប៉ះគ្នា" ៖ ២០-៣០

២១-សន្លាក់ថ្គាមដាច់រឹងអសមត្ថភាពញែកច្រានឆ្អឹងថ្គាមទាំងពីរច្រើនជាង ១០ម.ម ៖ ១៥-៤០

២២-បាត់បង់អណ្ដាតមួយភាគ វិបត្តិនៃពាក្យសំដី ៖ ២០-៣០

២៣-ថ្លង់ ឥ បណ្ដាលមកពីអនុភាព សម្ពាធខ្យល់ធ្លាក់នៃការផ្ទុះ

-ភាពធ្ងន់ធ្ងរ ៖ ៤០-៦០

-ធ្ងន់ធ្ងរមធ្យម ៖ ២០-៤០

ខ-ទ្រូង និងសរីរាង្គក្នុងទ្រូង ៖

១-បាក់ឆ្អឹងជំនី ខូចទ្រង់ទ្រាយឆ្អឹង "ទ្រូងបំប៉ោង" ជាមួយនឹងការរីករាលនៃដំបៅផ្ទុះប្លោងស្រោមសួត ៖ ២៥-៣៥

២-វិបត្តិនិងការរលាកនៃផ្ទៃនៃដំបៅស្រោមសួត "ខ្ទុះក្នុងស្រោមសួត ខ្យល់ក្នុងស្រោមសួត
ស្រោមសួតជាប់គ្នា អេតេឡិកតាស "អេម៉ូតូរ៉ាក់" ភីអ៊ូតូរ៉ាក់ បាទីស្តូរ៉ែត" ៖ ២០-៣០

៣-វះកាត់សួត "ពឺនូម៉ូណិចតូមី" សមត្ថភាពដកដង្ហើមថយចុះតិចជាង ៥០ភាគរយ ៖ ២៥-៣៥

៤-ការរួមតូចនៃបំពង់អាហារ មកពីការប៉ះទង្គិច ឬមកពីការលេបដោយគ្រោះថ្នាក់នៃរូបធាតុ
ឱ្យរលាក "ស៊ូដកូស្ទិច" ៖ ២០-៤០

គ-ឆ្អឹងខ្នង ៖

១-រឹងឆ្អឹងខ្នង ចលនានៃបំណត់ និងចង្កេះ មានលក្ខណៈប្លុយថយចុះ និងឈឺចាប់ ៖ ២៥-៤០

២-អាការៈរោគនៃកន្ទុយសេះ ទល់លាមកមិនពេញលេញ ៖ ១០-៣០

ឃ-ពោះ និងសរីរាង្គក្នុងពោះ ៖

១-វះកាត់ក្រពះ ៖

-គ្មានវិបត្តិ ៖ ២០-២៥

-មានវិបត្តិជាប់ជានិច្ច វិបត្តិនៃការរំលាយអាហារ សុខភាពទូទៅថយចុះ ៖ ២៥-៣៥

២-វះកាត់ពោះវៀនតូច លើសពីមួយម៉ែត្រ គ្មានវិបត្តិ និងគ្មានវិបត្តិដល់ការរំលាយអាហារ ៖ ២៥-៣០

៣-ជំងឺធ្លាយនៃពោះវៀន :

-រន្ធធ្លាយធំនៅភាគខាងលើ : ២៥-៤០

-រន្ធធ្លាយធំនៅភាគខាងក្រោម : ២០-៣០

៤-រន្ធធ្លាយតូចបណ្ដាលឱ្យហូរនូវខ្ទុះ និងទឹកលាមក "ឆាមករ៉ា" : ២០-៣០

៥-ការប៉ះពាល់ដល់ស្ពិនក្ទ័រទ្វារលាមក ជាមួយនឹងការបាត់បង់ "ជុះទប់មិនឈ្នះ" : ២៥-៣០

៦-ជំងឺថ្លើមជាមួយនឹងវិបត្តិនៃមុខងារថ្លើម : ១៥-៣០

៧-វះកាត់តម្រងនោមម្ខាង ម្ខាងទៀតធម្មតា : ២៥

ខ-ប្រដាប់ទឹកនោម និងប្រដាប់បន្តពូជ :

១-រន្ធរីកធ្លាយ "អ៊ុយរេត្រ" នៃរេចរ៉ៃណេ" : ២០-៤០

២-ការរួមតូចនៃទ្វារនោម "អ៊ុរេត្រ"

-តម្រូវឱ្យព្យាបាលដោយពង្រីកជារៀងរាល់ខែ : ១០-៣០

-ជាមួយនឹងរន្ធរីកធ្លាយ : ២៥-៤០

៣-កាត់លិង្គបុរសមានកូនរួចហើយ : ២៥-៣៥

៤-វះកាត់ស្បូនស្ត្រីអាយុតិចជាង៤៥ឆ្នាំ ដែលមានកូនរួចហើយ : ២៥-៣៥

៥-កាត់សុដន់ទាំងពីរចោលនៅស្ត្រីដែលមានកូនរួចហើយ : ២៥-៤០

៦-រន្ធធ្លាយពីផ្លោកនោមទៅទ្វារមាស "ផ្លោកនោម ទ្វារមាស" : ២០-៣០

គ-អវយវៈ :

១-បាត់បង់មេដៃ និងឆ្អឹងមេដៃ : ២៥-៣០

២-បាត់បង់ម្រាមដៃបួន មិនចំពោះម្រាមណា : ២៥-៣០

៣-បាត់បង់ម្រាមដៃទាំងប្រាំ : ៣០-៣៥

៤-ម្រាមទាំងប្រាំរឹងក្រញង់ : ២៥-៣០

៥-សន្លាក់ក្លៀកក្លាយ ខូចកន្លែង នៃឆ្អឹងកំភួនដៃទាំងពីរ : ២០-៣០

៦-កែងដៃរឹងក្រញង់ ដោយបត់បានត្រឹមពី ១១០-១៨០ អង្សា : ២៥-៤០

៧-បាក់ឆ្អឹងជើងដៃជាមួយនឹងសន្លាក់ក្លៀកក្លាយ : ២៥-៣៥

៨-បាក់កណ្ដាលនៃឆ្អឹងជើងដៃ ដែលឆ្អឹងមានគុណវិបត្តិជាមួយនឹងលក្ខណៈបន្ថយចុះនៃចលនារបស់ស្មា : ២៥-៣០

៩-ស្មារឹងក្រញង់ :

-កន្លែងកាច់ "អាប់ឌុចស្យុង" ពី ៤៥ អង្សា : ២៥-៣០

-កន្លែងកាច់ពី ១០ អង្សា : ៣០-៣៥

១០-ខ្វិនណឺរ៉ូ រ៉េដ្យង់ : ២៥-៣០

១១-ខ្វិនណឺរ៉ូ រ៉ាដ្យាល់នៅភាគខាងលើនៃទ្រីសិបស៍ ប្រ.អប់ដៃធ្លាក់ចុះវិករវាក់ : ២៥-៣០

១២-ខ្វិនឬសណឺរ៉ូខាងលើ "រ៉ាឌីគុយឡែរ" ធុនឌុចេនទំនើស "ខ្វិនសាច់ដុំ ដែលតូចអឹង ទ្រីសិបស៍ ប្រាចាល់មុខ និងឡុងស៊ូពីណាទ័រ" : ២៥-៣០

១៣-ខ្វិនឬសណឺរ៉ូខាងក្រោម ខ្វិនសាច់ដុំផ្ចុងចិតបបំម្រាមដៃ : ២៥-៣៥

១៤-អាការៈរោគវ៉ូលក្មេន "រួញ ឡូងរដ្ឋជីសស័រម្រាមដៃដោយហេតុរ៉ាំស្ពាយ ឡារីសាស្បូន

ប្រភពនៃការប៉ះទង្គិច : ២០-៣៥

១៥-បាត់បង់ម្រាមជើងទាំងប្រាំ និងឆ្អឹងបាតជើង : ២០-២៥

១៦-បាត់បង់ប្រអប់ជើង សល់តែការលោអួម " ឆ្អឹងកែងជើង " ឬកាត់សន្លាក់តាមរបៀប ឆូប៉ារតិ : ២៥-៣០

១៧-ការវះកាត់តាមរបៀបលីសហ្វ្រង់កិ រីការជិ ពីរ៉ូគួលហ្វិ : ២៥-៣០

១៨-កាត់សន្លាក់កជើង : ៣៥

១៩-បាក់ចាស់ឆ្អឹង ផ្លាតូទីប៊ីយ៉ា ជង្គង់រឹងក្រញង់ : ២០-៣០

២០-បាក់ឆ្អឹងស្មងទាំងពីរ ផ្សែឆ្អឹងមានគុណវិបត្តិ ស្មងវៀចជាមួយនឹងការរួញខ្លីលើសពី ៥ ស.ម : ២០-២៥

២១-សន្លាក់ក្លែងក្លាយនៃស្មង : ៣៥-៤០

២២-បាក់ ឬកាត់ត្រង់សន្លាក់អង្កុញ ជង្គង់រឹងក្រញង់ បស្ត្រិត ភ្លាត្រីសេបសិ : ១៥-២៥

២៣-កំរែល លេស្បុងនៃការប៉ះទង្គិចចំពោះដល់សន្លាក់ជង្គង់ ស្មងបត់បានពី ១៥០-១៣៥ អង្សា : ២០-៣០

២៤-បាក់មួយភាគបី កណ្តាលឬខាងក្រោម នៃឆ្អឹងភ្លៅ ផ្សែឆ្អឹងមានគុណវិបត្តិ អក្សរវៀច រួញខ្លីលើសពី ៤ ស.ម : ២០-៣០

២៥-បាក់មួយភាគបីខាងលើ ឬកឆ្អឹងភ្លៅ ផ្សែឆ្អឹងមានគុណវិបត្តិ ចង្វៀចនៃអ័ក្ស ពើចាប់នៅដំណើរ : ២៥-៣០

២៦-ជង្គង់រឹងក្រញង់ គ្មានវៀចឆ្អឹងភ្លៅ : ២៥-៣០

២៧-ជង្គង់រឹងក្រញង់វៀចឆ្អឹងភ្លៅ : ៣០-៣៥

២៨-សម្នាកមានគុណវិបត្តិនៃការលោកនៅសន្លាក់ជង្គង់ "កន្លាក់ភាចម៍ " ឬនៅជង្គង់ លក្ខខណ្ឌបន្ថយចុះដែលចលនាបត់និងលាស្មងជើងតិចជាង ៩០ អង្សា : ៣០-៣៥

២៩-ជំងឺរលាកឆ្អឹង និងខួរឆ្អឹង "អូស្តេអូម្យូលីក " រន្ធធ្លាយឆ្អឹងច្រើនកន្លែង និងសាររជាន" រឹងក្បាល : ២០-៤០

ឧបសម្ព័ន្ធទី ៤

ក-ក្បាល មុខ ក :

១-បាត់បង់មួយភាគនៃឆ្អឹងលលាដ៍ វិជ្ជមាត្រ ២ ស.ម : ១៥-២០

២-អន្ទការរីក្រាកម្លាង ខ្លាំងឡើងធម្មតា : ២៥

៣-ឆ្អឹងថ្គាមខាងលើ :

-បាត់បង់ធ្មេញភាគច្រើន គ្មានលទ្ធភាពដាក់ធ្មេញបាន : ២០

-បាក់មិនព្រើងពង្រួមបាននៃឆ្អឹងថ្គាមខាងលើ សមត្ថភាពទំពារថយចុះ : ២០-២៥

-សន្លាក់ធ្មេញវៀចតិចតួច : ១៥-២០

-ធ្លុះធ្លាយក្រអូមមាត់ ធ្លាយពីម្ខាងទៅម្ខាងរវាងមាត់ច្រមុះ : ២០-៣០

៤-ឆ្អឹងថ្គាមខាងក្រោម :

-បាក់មិនព្រើងពង្រួមបាននៃមែក "ប្រង់ចិ " ទទឹង" ចាត់ថ្នាក់ទៅតាម សមត្ថភាពទំពារ : ២០-២៥

៥-ភ្ជាត់ឆ្អឹងថ្គមសារជាន : ១០-២០

៦-កាត់អណ្តាតមួយភាគ រអាក់រអួលដល់ការនិយាយស្តី ការទំពារអាហារ និងការលេបអាហារ : ១០-២០

៧-ថ្លង់ទាំងសងខាង កំរិតមធ្យម : ២០-២៥

៨-កាត់ច្រមុះចោល តម្រូវឱ្យផ្លាស់ប្តូរមុខវិជ្ជាជីវៈ : ១០-២៥

៩-ជំងឺរលាកស៊ីនូសនៃថ្ពាម "ស៊ីនូសអ៊ីត" ថ្ងាស អេថ្មូអ៊ីត ចាត់ថ្នាក់ទៅតាមការធ្ងន់ធ្ងរនៃជំងឺ និងចំនួនស៊ីនូសដែលរងគ្រោះមានជំងឺ : ១០-៣០

១០-វិបត្តិ ពាក្យសំដី និងវិបត្តិដកដង្ហើមមានប្រភេទពីរ :

-ខ្វិនណឺរ៉ូរ៉េក្កូរេនតិ

-សម្ពាធទៅបំពង់សំលេង ដើមក

-ជំងឺរលាកសន្លាក់ក្រីកូ -អារីថេន័រអ៊ីដ :

. និយាយមិនឮ : ២០-៣០

.ហត់ដង្ហក់មធ្យម : ១៥-២០

១១-ការរំលោភប៉ះទង្គិចមកពីសម្ទុះខ្យល់ធ្លាក់នៃការផ្ទុះ

-អាការៈរោគផ្លាស់ខ្លួនជាប់បន្តពីការរញ្ជួយខួរ "សណ្ដានស្រាល" : ២០

-វិបត្តិនៃពាក្យសំដីនិងការស្ដាប់សួរសំលេងអាគ្នឺតេត្រចៀកធ្លាក់ចុះ : ១១-២០

-ជំងឺចាំស៊ីដូរ៉ា "ពពក" កើតឡើងនៅប៉ុន្មានខែដំបូងក្រោមការប៉ះទង្គិច : ៥-២០

-យ៉ាំបែតផ្អែម "ទឹកនោមផ្អែម" ជាប់បន្តពីការប៉ះទង្គិចលលាដ៍ ឬការបុកទង្គិច : ២៥

១២-ជំងឺស្រួយរំផ្អកទន់ "សាច់ដុំ" នៅស្នាមជុំឃនឹងស្នាមជុំនៃសាច់ដុំក និងមុខ : ១៥-២០

ខ-ទ្រូង និងសរីរាង្គក្នុងទ្រូង :

១-វះកាត់ក្លេបសួត "ឡូបេកតូមី" ជាមួយនឹងសមត្ថភាពដកដង្ហើមថយចុះតិចតួច : ១៥-២០

គ-ពោះ និងសរីរាង្គក្នុងពោះ :

១-ដំណំ "កាត់ភ្ជាប់ ក្រពះ ពោះវៀន" : ១៥-២០

២-ស្ទះពោះវៀន វះកាត់ឡើងវិញ មកពីវិបត្តិនៃអន្តរាគមន៍វះកាត់ចាស់នៃពោះវៀន : ១៥-២៥

៣-វះកាត់ពោះវៀនតូច "តិចជាងមួយម៉ែត្រ" : ២០-២៥

៤-កាត់ថ្លើមចោលមួយក្លែប : ២០-២៥

៥-វះកាត់ជាល "អណ្ដើក" ធនរោគទឹកមធ្យម : ១៥-៣៥

ឃ-ត្រួតរាក សរីរាង្គនៃត្រួតរាក អង្គជាតិ :

១-កាត់ពងស្វាសចោលទាំងពីរ លើបុរសអាយុលើសពី ៥០ ឆ្នាំ : ១០-២០

២-វះកាត់ស្បូនចំពោះស្ត្រីអាយុលើសពី ៤៥ ឆ្នាំដែលមានកូន : ២០-២៥

៣-សម្ពាធច្រើនអាទ្រីនៃទ្វារមាស និងយោនី : ១០-២៥

៤-កាត់សុដនចោលម្ខាងនៅស្ត្រី ឬក្មេងស្រី : ១០-២០

៥-បាក់ឆ្អឹងតូច ជាមួយនឹងវិបត្តិសាច់ដុំលើង និងស : ២០-២៥

ង-អវយវៈ :

១-បាត់បង់មេដៃ និងឆ្អឹងបាតដៃ : ១៨-២១

២-ចង្អុល និង ម្រាមដៃពីរទៀត ក្រៅពីមេដៃ : ២០-២២

៣-បាត់បង់មេដៃ និងម្រាមដៃមួយទៀត ក្រៅពីចង្អុលដៃ : ២០-២២

៤-បាត់បង់មេដៃ និងម្រាមដៃពីរទៀត ក្រៅពីចង្អុលដៃ : ២០-២៥

៥-សម្ពាធធំនៃការរលាកប្រអប់ដៃ, ម្រាមដៃរឹង និងក្រញ៉ាង ឬមិនលា ចត់បាន :

-ម្រាមដៃទាំងប្រាំ : ២៥-៣០

-ខេ និងចង្កូលដៃ	:	២០-២៥
-ខេ និងម្រាមដៃមួយទៀត	:	១៥-២០
៦-សន្លាក់មានគុណវិបត្តិនៅកែងដៃ ដែលកំណត់ចលនាកំភួនដៃ :		
-លាតសន្ធឹងពី ១៨០ មក ១១០ អង្សា	:	២០-២៥
-បំណត់ពី ១១០ មក ៧៥ អង្សា	:	១៥-២០
-បំណត់ពី ៧៥ មក ៣៥ អង្សា	:	១០-១៥
៧-សន្លាក់មានគុណវិបត្តិនៅស្មៀក ដែលកំណត់នៅចលនាស្មា :		
-លើកដៃ កន្លែករចញពី ៤៥ អង្សា	:	១០-២៥
-លើកដៃកន្លែករចញពី ១០ អង្សា	:	២៥-៣០
៨-សន្លាក់ដើរឹងក្រញូង ជាមួយនឹងចលនាចម្ងាយក្រោមដៃ :		
-ឥរិយាបថនៃមុខងារ "ធ្វើការងារ"	:	១៥-២០
-ឥរិយាបថកោង	:	២០-២៥
៩-បាក់ឆ្អឹងកំភួនដៃទាំងពីរ ដែលឆ្អឹងមានគុណវិបត្តិ ម៉ាស្រៀច រួញខ្លី	:	១៥-២៥
១០-រឹងដើរឹងក្រញូងជាមួយនឹងចំណត់ជើងកំភួនដៃពី ៦០ ទៅ ១១០ អង្សា	:	១៥-២៥
១១-ស្ពឹងក្រញូង ជើងដៃកន្លែករចញពី ៩០ អង្សា	:	១០-២៥
១២-ខ្វិនណើរ មេដៃប់ អាកាំខ្ចងកដៃ	:	២០-២៥
១៣-ខ្វិនណើរ ក្ដូបិនាល់	:	១៥-២៥
១៤-ខ្វិន ម្រាមដៃនៅខាងក្រោយទ្រឹសាចស៍	:	២០-២៥
១៥-បាក់ឆ្អឹងជង្គង់ចិង ដែលឆ្អឹងមានគុណវិបត្តិជាមួយនឹងសញ្ញាញៀបញៀរណើរ	:	១៥-២៥
១៦-បាក់ឆ្អឹងស្មាបប្រទៀវ	:	១០-៣០
១៧-បាត់បង់ម្រាមជើងប្រាំ	:	៥-១០
១៨-បាត់បង់ឆ្អឹងអាំស្រ្តាគ្គាល	:	២៥
១៩-បាត់បង់ឆ្អឹងកែងជើង	:	២៥-៣០
២០-សន្លាក់ឆ្អឹងកជើងរឹងក្រញូង	:	១៥-២០
២១-បាត់បង់ភ្លោកកោលទាំងពីរ ស្ទូងវៀច	:	១៥-២០
២២-បាក់ឆ្អឹងល្ងួងទាំងពីរ "ទីប៊្យា និងប៉េរ៉ូណេ" ដែលឆ្អឹងមានគុណវិបត្តិ ស្ទូងវៀច		
រួញខ្លីតិចជាង ៥ ស.ម	:	១៥-២០
២៣-ឈឺល្អុង ជង្គង់ ឥរិយាបថមុខគ្រោះចលស្នូង "១៣៥-១៨០ អង្សា"	:	១៥-២០
២៤-អង្គធាតុជំនៅក្នុងសន្លាក់ជង្គង់	:	១០-២៥
២៥-ជង្គង់រឹងក្រញូង ឥរិយាបថស្ដាំនៃស្នូង "១៨០ អង្សា"	:	១៥-២៥
២៦-សន្លាក់មានគុណវិបត្តិនៃការលោកនៃសន្លាក់ជង្គង់ "កន្លាក់នាចទី" ឬនៅជង្គង់កំណត់		
ចលនាបត់ និងលាពី ៩០ - ១៣៤ អង្សា	:	១០-៣០
២៧-ជាប់ស្នូង សន្លាក់មានគុណវិបត្តិជាមួយនឹងការរួញខ្លីនៃសរសៃកង "តង់ផុងអាស៊ីល"	:	១៥-២៥
២៨-បាក់មួយភាគបីខាងលើនៃឆ្អឹងភ្លៅ ឬក៏ឆ្អឹងភ្លៅ ដែលឆ្អឹងមានវិបត្តិលាត់ផ្ទុំខាងក្រោយវៀច		
ឈើច្រត់នៅពេលដើរ	:	២៥-៣០
២៩-ខ្វិនណើរស្បាទីន	:	២៥

៣០-ឈឺចាប់នៃឈឺរុំស្បាទីត ចាត់ថ្នាក់ទៅតាមកំរិតនៃការឈឺចាប់ និងកំរិតនៃការលំបាក ដំបិនទៅដំណើរ	៖	១០-២៥
៣១-ភ្នាត់ឆ្អឹងចង្កេះ និង រឹងក្រញ៉ាប់	៖	២០-២៥
៣២-ជំងឺរលាកឆ្អឹង និងខួរ ជាមួយនឹងរន្ធធ្លាយច្រើនអឆ្អឹ និងសារជាតិ	៖	២០-៣០
៣៣-ស្វិតសាច់ដុំ ឈឺចាប់ ជាំរ៉ាំរ៉ៃសុីអវៈយវៈមកពីការព្យាបាលដោយសៀមអប់ទីតេតាណិច	៖	២០
៣៤-ការឈាប្រឹស្មអាវ៉ែម រឹង នៃអវៈយវៈ ចាត់ថ្នាក់ទៅតាមវិបត្តិនៃរបត់ឈាម និង វិបត្តិនៃមុខងារផ្លាស់ប្តូរកន្លែង	៖	៥-២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៧៤៧៥ប្រ.ក

ប្រកាស

ស្តីពីការបង្កើត ការិយាល័យរដ្ឋបាល និងសរុប
ចំណុះនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ
នៃ អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- យោងប្រកាសលេខ ០៩៥ ប្រ.ក ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សំរេច

ប្រការ ១ : ត្រូវបង្កើតអោយមានការិយាល័យមួយឈ្មោះថា "ការិយាល័យរដ្ឋបាល និងសរុប "។

ប្រការ ២ : ការិយាល័យរដ្ឋបាល និងសរុប ស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។

ប្រការ ៣ : ការិយាល័យរដ្ឋបាល និងសរុប ដឹកនាំដោយប្រធានការិយាល័យមួយរូប អមដោយអនុប្រធានការិយាល័យពីររូប ជាជំនួយការ ។

ប្រការ ៤ : ការិយាល័យរដ្ឋបាល និងសរុប មានតួនាទី ភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

- ទទួលបន្ទុកលើការងារលិខិតចេញ ចូល លេខហារី ទូរស័ព្ទ និងទូរសារ ៤

- ធ្វើការបែងចែកលិខិតចូល ទៅអោយការិយាល័យពាក់ព័ន្ធចំណុះនាយកដ្ឋាន តាមចំណារ របស់ប្រធាននាយកដ្ឋាន ។
- ធ្វើការបែងចែក និងផ្ញើរចេញ នូវលិខិតស្នាមទាំងឡាយដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចុះហត្ថលេខា និងបោះត្រារួចស្រេចហើយ ។
- រៀបចំសំណុំលិខិតនានា ដាក់ជូនប្រធាននាយកដ្ឋានពិនិត្យ ។
- ទទួលខុសត្រូវលើការថែរក្សាច្បាប់ លិខិតបទដ្ឋានទាក់ទងការងារបុគ្គលិក និងតម្កល់ឯកសារ ។
- ចាត់ចែងសំអាត តុបតែង លំអ និងការងារពិធីការ របស់នាយកដ្ឋាន ។
- រៀបចំ គំរោងចំណាយថវិកា និងការផ្គត់ផ្គង់មធ្យោបាយសំភារៈរដ្ឋបាល សំដៅអោយការងារនៅនាយកដ្ឋាន ដំណើរការមាននិរន្តរភាព និងប្រសិទ្ធភាព ។
- ទទួលបើកប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ប្រេងឥន្ធនៈ ជូនមន្ត្រីរាជការនៅក្នុងនាយកដ្ឋាន ។
- ធ្វើរបាយការណ៍បូកសរុបការងារ ប្រចាំសប្តាហ៍ អឌ្ឍមាស ខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ និង និង បូកសរុបទិសដៅការងារ របស់នាយកដ្ឋាន ។
- ពិនិត្យ បូកសរុប វិភាគ វាយតម្លៃ សន្និដ្ឋានលើរបាយការណ៍ពីគ្រប់ការិយាល័យ ចំណុះនាយកដ្ឋាន ជូនប្រធាននាយកដ្ឋាន ពិនិត្យ សំរេច ។
- ចូលរួមធ្វើកំណត់ហេតុក្នុងអង្គប្រជុំនានារបស់នាយកដ្ឋាន ។
- បំពេញការងារផ្សេងៗទៀតតាមការចាំបាច់ និងតាមការប្រគល់ភារកិច្ចពីប្រធាននាយកដ្ឋាន ។

ប្រការ ៥ : អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាល គ្រប់ខេត្ត ក្រុង ប្រធាននាយកដ្ឋាន ចំណុះអគ្គនាយកដ្ឋានរដ្ឋបាល និង អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០០២

សហរដ្ឋមន្ត្រី

ស ខេង   យូ ហុកគ្រី

ចម្លងជូន

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
  (ដើម្បីជូនជ្រាប)
- *ដូចប្រការ ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*